**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 31-Oct-2014, 14:59
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៣/០៧-០៩-២០០៩-អវតក/កសចស |
| ដាក់ទៅ | : | សហចៅក្រមស៊ើបអង្កេត |
| ថ្ងៃដាក់ | : | ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ ក.ស.ច.ស: សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ**
**ស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង០០៣**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញាអន្តរជាតិ:
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

ការិ.សហចៅក្រមស៊ើបអង្កេត:
ចៅក្រម Mark B. HARMON
ចៅក្រម យូ ប៊ុនឡេង

**ចម្លងជូន:**

**ចម្លងជូន:**

សហព្រះរាជអាជ្ញាជាតិ:
លោកស្រី ជា លាង

## I. សេចក្ដីផ្ដើម

១- អនុលោមតាមវិធាន៥៣ និងវិធាន៥៥នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិ(“សពអ”) សូមដាក់ជូននូវសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលខ្លួនមានបំណងចង់បញ្ជាក់បំភ្លឺ និងបន្ថែមជូននូវបញ្ហានានាទាក់ទងខាងអង្គហេតុ ដែលត្រូវស៊ើបសួរដោយសហចៅក្រមស៊ើបអង្កេត (“សចស”) នៅក្នុងសំណុំរឿងលេខ០០៣។

២- នៅក្នុងគោលបំណងដើម្បីបញ្ជាក់បំភ្លឺ ការដាក់ជូននូវឯកសារនេះសូមបញ្ជាក់អះអាងជាថ្មីឡើងវិញអំពីការបញ្ជាក់បំភ្លឺទាំងឡាយកាលពីមុនដោយសហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការដាក់ឯកសារផ្សេងៗទាក់ទងអំពីវិសាលភាពនៃកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង០០៣ និងការដាក់សេចក្តីបញ្ជាក់បំភ្លឺបន្ថែមទៀតដែលទាក់ទងនឹង៖(ក)ការបោសសំអាតនានាដែលបានដឹកនាំដោយ មាស មុត និងកងយោធានៃកងពលធំលេខ១៦៤របស់គាត់ នៅក្នុងតំបន់៥០៥(ក្រចេះ) និង (ខ)ការធ្វើពលកម្មដោយបង្ខំ និងការសម្លាប់មនុស្សនៅក្នុងឃុំរាម ស្រុកព្រៃនប់(II. ការបញ្ជាក់បំភ្លឺ, កថាខណ្ឌពីទី៤ ដល់ទី១៩)។

៣- តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះ សហចៅក្រមសើបអង្កេតក៏ក្តាប់បានផងដែរអំពីឧក្រិដ្ឋកម្មបន្ថែមស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ (រាប់បញ្ចូលទាំងអំពើចាប់រំលោភសេពសន្ថវៈផង) ដែលផ្អែកលើមូលដ្ឋាននៃភស្តុតាងនានាដែលប្រមូលបានដោយ កសចស ក្រោយពីដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ (“Second IS”)។ អង្គហេតុបន្ថែមនានានៃឧក្រិដ្ឋកម្ម មានរៀបរាប់ជូនខាងក្រោមនេះ នៅក្នុងកថាខណ្ឌពីទី២០ ដល់ទី២៤(III. ទីតាំងឧក្រិដ្ឋកម្មបន្ថែម) ហើយដែលត្រូវបានគេជឿថានៅក្នុងយុត្តាធិការនៃ អវតក ។ សហព្រះរាជអាជ្ញាអន្តរជាតិសូមស្នើ ឲ្យអង្គហេតុនៃឧក្រិដ្ឋកម្មទាំងនេះក្លាយទៅជាផ្នែកនៅក្នុងសំណុំរឿង០០៣។

## II. ការបញ្ជាក់បំភ្លឺ

*ឧក្រិដ្ឋកម្មនានាដែលមិនស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ*

៤- ជាការឆ្លើយតបទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលសុំឲ្យធ្វើការបញ្ជាក់បំភ្លឺទាក់ទងនឹងកងពលនានានៃកងទ័ពបដិវត្តកម្ពុជា(RAK) និងទីតាំងនៃការបោសសំអាតនានាផ្សេងទៀត[1] សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់ច្បាស់ កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ ថា កសចស មិនត្រូវបានជូនដំណឹងឲ្យដឹងអំពីស៊ើបសួរលើមន្ទីរសន្តិសុខនានារបស់កងពលធំទាំងអស់នៃកងទ័ពបដិវត្តកម្ពុជា ឬទីតាំងឧក្រិដ្ឋកម្មនានាផ្សេងទៀតក៏មិនត្រូវបានជូនដំណឹងឲ្យដឹង លុះត្រាតែអង្គហេតុទាំងនេះសំដៅឆ្ពោះទៅបង្ហាញឲ្យឃើញអំពីការបង្កើតជាសហឧក្រិដ្ឋកម្មរួម ឬអំពីការកើតឡើងឧក្រិដ្ឋកម្មមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធ[2]។ ត្រូវបានបញ្ជាក់បំភ្លឺបន្ថែមទៀតទាក់ទងអំពីមន្ទីរសន្តិសុខរបស់កងពលធំលេខ៨០១ ដូចដែលបានរៀបរាប់នៅក្នុងកថាខណ្ឌទី៦៣ និងទី៦៤នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ ("Second IS")។ កសចស មិនត្រូវបានគេជូនដំណឹងឲ្យដឹងអំពីការស៊ើបសួរបន្ថែមលើមន្ទីរសន្តិសុខអូរកន្សែង[3]។ ជាការឆ្លើយទៅនឹងសំណើសុំឲ្យបញ្ជាក់បំភ្លឺរបស់ សចសអ អំពីគុកលេខ៨១០ និងមន្ទីរសន្តិសុខ៨០៨ ឬ៨០៩ នៅក្នុងស្រុកវ៉ុនសៃ[4] សពអ បានពន្យល់ថា ការចោទប្រកាន់នានាទាក់ទងនឹងគុកលេខ៨១០ "មិនគួរត្រូវបានអានថាជាប់ទាក់ទងគ្នានឹងមន្ទីរសន្តិសុខ៨០៨ ឬ៨០៩ទេ"[5] និងថា កសចស "មិនត្រូវបានតម្រូវឲ្យដឹកនាំធ្វើកិច្ចស៊ើបសួរបន្ថែមទាក់ទងនឹងគុកឃោធាលេខ៨០១ នៅក្នុងស្រុកបានលុង (មន្ទីរសន្តិសុខអូរកន្សែង)" [6]។

៥- កាលពីថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបានជូនដំណឹងអំពី "អង្គហេតុថ្មី"ដែលត្រូវបានចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងលោកចៅក្រម Kasper-Ansermet ("សចសអប") នៅក្នុងដីកាបញ្ជូនរឿងទៅពិនិត្យ[7] ដែលបានលេចឡើងដោយ

---

[1] ឯកសារលេខ **D1/2** សំណើសុំការបញ្ជាក់បំភ្លឺនៅក្នុងសំណុំរឿង០០៣, ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១។

[2] **D1/2/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំការបញ្ជាក់បំភ្លឺ, ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌទី២។

[3] ហើយក៏ត្រូវបានគេហៅថា សាលាអប់រំកែប្រែនៃកងពលធំលេខ៨០១ ឬ លេខ៨១០, គុកឃោធា ៨០១ និងមន្ទីរសន្តិសុខភូមិបី ផងដែរ។

[4] ឯកសារលេខ **D105** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យទាក់ទងនឹងមន្ទីរសន្តិសុខ ៨០៨, ៨០៩ និង ៨១០, ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤។

[5] ឯកសារលេខ **D105/1** ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ទាក់ទងនឹងមន្ទីរសន្តិសុខ៨០៨, ៨០៩ និង ៨១០, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៤។

[6] ឯកសារលេខ **D105/1** ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យទាក់ទងនឹងមន្ទីរសន្តិសុខ ៨០៨, ៨០៩ និង ៨១០, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៤, កថាខណ្ឌទី៣។

[7] ឯកសារលេខ **D50** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ, ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១២។

សារលទ្ធផលនៃការស៊ើបអង្កេតដល់មូលដ្ឋានទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម។ សពអ កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ បានចាត់ទុកថា កិច្ចស៊ើបសួរបន្ថែមទៅលើអង្គហេតុថ្មីនានាដែលបានចោទប្រកាន់ មិនត្រូវបានធ្វើយុត្តិកម្មថា អង្គហេតុពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរឲ្យហួសពីអង្គហេតុស្នូលនៃសំណុំរឿង០០៣ និងមិនបណ្តាលឲ្យការស៊ើបសួរដែលកំពុងតែបន្តធ្វើ បំពេញបានដោយប្រសិទ្ធភាពឡើយ[8]។

*ឧក្រិដ្ឋកម្មនានាដែលបានដាក់បញ្ចូលនៅក្នុងការស៊ើបសួរ*

**ចំការធូរេន និង បិតត្រាំង**

៦- កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង (“សចសអប”) អនុវត្តតាមវិធាន៥៥(៣)នៃវិធានផ្ទៃក្នុង បានបញ្ជាក់ថា មានអង្គហេតុថ្មីៗមួយចំនួនបានលេចឡើងនៅក្នុងកិច្ចស៊ើបសួរដែលនៅក្នុងនោះរួមបញ្ចូលនូវទីកន្លែងសម្លាប់មនុស្សរបស់កងពលធំលេខ១៦៤ ដែលនៅក្នុងនេះហៅថា “ចំការធូរេន” (ដែលមានទីតាំងស្ថិតនៅភូមិរាម ឃុំរាម ស្រុកព្រៃនប់) និងការដ្ឋានពលកម្មដោយបង្ខំ និងមន្ទីរអប់រំកែប្រែ បិត ត្រាំង (ទីតាំងដែលនៅជុំវិញនោះ)[9]។

---

[8] ឯកសារលេខ **D50/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១២, ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២, កថាខណ្ឌពីទី៩ ដល់ទី១០។

[9] ឯកសារលេខ **D47** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ, ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២។ បិទ ត្រាង ក៏ត្រូវបានគេហៅដោយឈ្មោះផ្សេងៗគ្នាមួយចំនួនផងដែរ, ដែលរួមមាន៖ ចំណោតរាម និងអូរប្រៃ (O’Prai)។ ចំណែកឯឈ្មោះ “ចំណោតរាម” ‘Chamnoat Ream’ , គឺជាប្រភពដែលនាំឲ្យមានការច្រឡំគ្នាជាមួយនឹង ភូមិ ឬឃុំរាម, សូមមេត្តាអានឯកសារលេខ **D54/26** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ប៉ាក សុខ (Pak Sok), ត្រង់ (A26 – A29) [“ក្នុងឆ្នាំ១៩៧៦, យោធាខ្មែរក្រហមបានយកប្រជាជន១៧មេសា ទាំងអស់ចេញពីភូមិស្មាច់ដែង (Smach Daeng Village), ភូមិគគីរ, និងចំណោតរាម ហៅ បិត ត្រាំង ដើម្បីយកទៅសម្លាប់នៅត្រង់ចំនុចចំណោតរាមនោះ”]។ ឯកសារលេខ **D22/1998/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចាន់ សូវុន (Chan Soevun) (របាយការណ៍របស់អង្គភាព DSS ) ត្រង់លេខ ERN ជាភាសាអង់គ្លេសat EN 00541435។ រីឯឈ្មោះ អូរ ប្រៃ ‘Au Prai’ វិញ, ឯកសារលេខ **D54/18** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ នូ សារឿន (Nou Saroeun) ដែលស្រង់ដោយ កសចស ត្រង់ចម្លើយឆ១១-១២ (A11-A12) [“សហករណ៍នោះស្ថិតនៅឃុំរាម ដែលឥឡូវគេហៅឃុំ បិត ត្រាំង វិញ។ នៅទីនោះពីដើមគេហៅទំនប់អូរប្រៃ នៅក្នុងភូមិពូធឿង(Pu Thoeung Village) ឃុំរាម ទេ, មិនមែនហៅថាឃុំ បិត ត្រាំង ទេ …តាមពិតបន្ទាប់ពីឆ្នាំ១៩៧៩ គេហៅទីនោះ ថា បិត ត្រាំង ។ កាលពីមុនគេហៅថា ទំនប់អូរ ប្រៃ(Tumnup Au Prai), ភូមិពូ ធឿង (Pu Thoeung Village), ឃុំរាមទេ។ ខ្មែរក្រហមនៅភូមិពូធឿង បន្ទាប់ពីឆ្នាំ១៩៧៥។”]។ ឯកសារលេខ **D54/22** កំណត់ហេតុស្តីពីកិច្ចស៊ើបសួរ, ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣, ត្រង់លេខ ERN ជាភាសាអង់គ្លេស 00947618។

កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថាខ្លួនបានចាត់ទុកថា កសចស បានទទួលរួចហើយទាក់ទងទីតាំងទាំងពីរនេះ ក៏ប៉ុន្តែពុំចាំបាច់ឲ្យមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនោះទេ អង្គហេតុទាំងនេះគឺជាអង្គហេតុដែលថ្មីដោយផ្នែកខ្លះតែប៉ុណ្ណោះ ហើយជាប់ទាក់ទងជាមួយនឹងអង្គហេតុនានាដែលមានស្រាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ[10]។ ទាំងប្រជាជនស៊ីវិល និងទាំងពួកយោធិននៃកងពលធំលេខ១៦៤ គឺសុទ្ធតែត្រូវបានដាក់ឲ្យស្ថិតនៅក្នុងការធ្វើពលកម្មដោយបង្ខំ ឬត្រូវបានគេសម្លាប់នៅតាមបណ្តាការដ្ឋានទាំងនោះ រួមទាំង "ប្រជាជនថ្មី"[11] និងជនជាតិវៀតណាមផង[12]។

**កងកេង**

៧- ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ (Second IS) បានលើកឡើងអំពីសារៈសំខាន់របស់កងកេងក្នុងកថាខណ្ឌ៨៦(ក) ដោយរៀបរាប់ថា មាស មុត ក្នុងនាមជាលេខកងពលធំលេខ១៦៤ មានភារកិច្ចត្រូវទទួលខុសត្រូវក្នុងការការពារឆ្នេរសមុទ្ររបស់ប្រទេសកម្ពុជា ដែលក្នុងនោះ

---

[10] ឯកសារលេខ **D47/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យចុះកាលបរិច្ឆេទថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២, ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២, កថាខណ្ឌទី៥។

[11] ឯកសារលេខ **D54/26** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ ប៉ាក សុខ (Pak Sok) ដែលស្រង់ដោយ កសចស, ត្រង់ (A26) ["ក្នុងឆ្នាំ១៩៧៦, យោធាខ្មែរក្រហម [បុគ្គលិកនៃកងពលធំលេខ១៦៤] បានយកប្រជាជន១៧ មេសា ទាំងអស់ ចេញពីភូមិស្នាច់ដែង, ភូមិគគីរ, និងពីចំណោតរាម ហៅ បិត ត្រាំង(Chamnaot Ream alias Bet Trang) ដើម្បីយកទៅសម្លាប់នៅត្រង់ចំណុចចំណោតរាមនោះ"], ចម្លើយឆ២៨ (A28) ["យោធាទាំងនោះបាននិយាយប្រាប់ខ្ញុំថា ប្រជាជន១៧ មេសាទាំងនោះ ត្រូវគេសម្លាប់ទាំងអស់"]។

[12] ឯកសារលេខ **D54/26** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ ប៉ាក សុខ (Pak Sok) ដែលស្រង់ដោយ កសចស , ត្រង់ (A11-13) ["សំណួរ១១ (Q11): តើលោកធ្លាប់បានឮកន្លែងចំការធូរេននៅរាម ដែលនៅជិតកន្លែងចំការដូងដែរឬទេ?-ចម្លើយឆ១១ (A11): បានខ្ញុំធ្លាប់ស្គាល់ទីកន្លែងនោះ។ កន្លែងទាំងនោះជាកន្លែងដែលយួនជាច្រើនត្រូវគេសម្លាប់។ សំនួរ: លោកអាចប្រាប់យើងបានទេថា តើមានយួនប៉ុន្មាននាក់ដែលត្រូវបានគេសម្លាប់នៅទីនោះ? -ចម្លើយឆ១២ (A12): តាមខ្ញុំដឹងគឺមានយួនរាប់រយនាក់ ត្រូវបានគេសម្លាប់នៅទីនេះ។ សំនួរ: តើយោធាណានៅកងណា ដែលបោះទីតាំងនៅកន្លែងនោះ?-ចម្លើយ១៣ (A13): មានមួយកងវរសេនាតូចមួយដែលមានយោធាប្រហែល១៥០នាក់ របស់កងវរសេនាធំដែលបោះទីតាំងប្រចាំនៅទីនោះ។ តួនាទីរបស់ យោធាទាំងនោះគឺ សំរាប់ទទួលយួនដែលគេចាប់បាន យកទៅសម្លាប់នៅឯចំការធូរេន ចំការដូង និងចំការក្រូច។ ចំការធូរេន ចំការដូង និងចំការក្រូចនៅជិតគ្នា"]។ ចម្លើយ១៦ (A16): ["[យោធាដែលធ្វើការនៅទីនោះ] គេប្រាប់យើងថា គេបានសម្លាប់យួនជាច្រើននៅទីនោះ ហើយកប់សពនៅក្រោមដើមធូរេនដើម្បីធ្វើជី"]។

រួមមានទាំងទីប្រជុំជន កងកេង ផងដែរ[13]។ លើសពីនេះ នៅក្នុងចម្លើយតបរបស់ខ្លួនកាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ ទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យរបស់ កសចស[14], សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់បំភ្លឺថា មូលហេតុមួយក្នុងចំណោមមូលហេតុជាជម្រើសនានាផ្សេងទៀតជាច្រើនដែលធ្វើយុត្តិកម្មថា ការដ្ឋានបិតត្រាំង តែត្រូវចាត់ទុកថាជាផ្នែកនៃវិសាលភាពនៃកិច្ចស៊ើបសួរ គឺជាទីតាំងភូមិសាស្ត្រដែលនៅជិតខាងគ្នា ឬក៏ជាអត្តសញ្ញាណនៃទីតាំងរវាង បិតត្រាំង និង កងកេង[15] ដែលបង្កប់ន័យថា ទីតាំងចុងក្រោយនេះ ត្រូវបាន សពអ ចាត់ទុកថា ត្រូវបានដាក់បញ្ចូលរួចហើយនៅក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ។ ដោយយោងទៅលើកថាខណ្ឌទី៨៦(ក)នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ សពអ បានថ្លែងថា ការលើកយោងទៅលើ "ទីប្រជុំជន" នៃ កងកេង អាចត្រូវបានអានដោយត្រឹមត្រូវ គឺចង់សំដៅទៅលើព្រលានយន្តហោះដែលឈ្មោះដូចគ្នានេះ។

៨- សពអ ឥឡូវនេះបញ្ជាក់បំភ្លឺថែមទៀតថា ការដ្ឋានពលកម្មដោយបង្ខំ និងមន្ទីរអប់រំកែប្រែនៃព្រលានយន្តហោះ កងកេង ដែលមានប្រជាជនស៊ីវិល និងយោធិននៃកងពលធំលេខ១៦៤ដែលមានចំនួនច្រើនបានទៅធ្វើការនៅទីនោះ យ៉ាងហោចមានរួមដូចខាងក្រោមនេះ៖

(ក) ឡឥដ្ឋមួយ[16]។

(ខ) "កងផលិតធំមួយ" និងកងចល័ត[17] ដែលបានធ្វើការលើការងារផ្សេងៗទាក់ទងនឹងការធ្វើស្រែ និងគំរោងកសាងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់ កងកេង[18] ដូចជា ចំការដំណាំ

---

[13] ឯកសារលេខ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ , កថាខណ្ឌទី៤២ និងទី៨៦(ក)។ ឯកសារលេខ **D47/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងដីកាបញ្ជូនសំណុំរឿងរឿងទៅពិនិត្យចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២, ចុះកាលបរិច្ឆេទថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ កថាខណ្ឌទី៨។

[14] **D47/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងដីកាបញ្ជូនរឿងចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ កថាខណ្ឌទី៨។

[15] បិត ត្រាំង មានទីតាំងស្ថិតនៅតាមដងផ្លូវជាតិលេខ៤ នៅជិតព្រលានយន្តហោះ កងកេង ក្នុងស្រុកព្រៃនប់, ក្រុងព្រះសីហនុ។ ទីតាំងទាំងពីរនេះហាក់ដូចជាមានចម្ងាយពីរ ឬបីគីឡូម៉ែត្រពីគ្នា ក្នុងរង្វង់ចម្ងាយដែលអាចមើលគ្នាឃើញ។

[16] ឯកសារលេខ **D54/17** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ សាយ ប៊ន (Say Born) ដែលស្រង់ដោយ កសចស, ត្រង់លេខ Q14 ["លោកបានចង្អុលបង្ហាញពីទីតាំងឡឥដ្ឋដែលនៅជិតព្រលានយន្តហោះកងកេង តាមបណ្តោយផ្លូវទៅរាម។ តើលោកមានដឹងពីអ្វីខ្លះពីទីកន្លែងនោះទេ? ចម្លើយ១៤(A14): វាជាការកន្លែងការដ្ឋានពលកម្មធម្មតារបស់កងពល១៦៤។ ខ្ញុំធ្លាប់បានមកទីនេះម្តងនៅចុងឆ្នាំ១៩៧៥។ (…) អ្នកធ្វើពលកម្មនៅទីនោះមានជនស៊ីវិល និងជាយោធា"]។

[17] ឯកសារលេខ **D54/43** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ លុន សេង (Lon Seng) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយ១៩ (A19) ["ភូមិពុទ្ធទេ នៅខាងជើងផ្លូវជាតិលេខ៤, ឆ្លងផ្លូវល់មកពីវាលហោះកងកេង។ កន្លែងនោះជាកន្លែងដែលកងពល១៦៤បានចាត់តាំងកងផលិតមួយកង ហៅថាកងផលិតធំ ដែលត្រូវបោះទីតាំងនៅទីនោះ"]។ ឯកសារលេខ **D54/43**

ផ្សេងៗ និងទំនប់[19] ដែលមានមួយចំនួនក្នុងចំណោមនេះមានទីតាំងនៅភូមិព្រែកចក, ប្របុស[20] និង ពូធឿង[21] និង

(គ) ចំការដូងមួយ ដែលគេស្គាល់ថា "ចំការចេង ហេង" ដែលដំណើរការនៅ កងកេង នៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[22]។

---

កំណត់ហេតុស្តាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សររបស់ លន សេង (Lon Seng) ត្រង់ចម្លើយ១៧ (A17) ["ខ្ញុំបានឃើញមន្ត្រីៗ ដែលធ្លាប់នៅកងវរសេនាតូច បែរជាធ្វើការនៅក្នុងកងផលិតកម្មទៅវិញ"]។

18 ឯកសារលេខ **D2/6** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ ញូង ជ្រោង (Nhoung Chrong) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយឆ២៤ (A24) ["អ្នកធ្វើការនៅទីនោះរួមមាន ប្រជាជន កងផលិត និង កងទ័ព"] ។ ឯកសារលេខ **D54/36** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ ប្រាក់ សុខា (Prak Sokha) ដែលស្រង់ដោយ កសចស, ត្រង់លេខ ERN ជាភាសាអង់គ្លេស 00977302 ត្រង់ចម្លើយឆ២២ (A22) ["ពួកយើងបានជីកប្រឡាយ និងធ្វើស្រែ"]។

19 ឯកសារលេខ **D2/6** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ ញូង ជ្រោង (Nhoung Chrong) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយឆ២៤ (A24) [" កងវរសេនាធំលេខ២២ ជាអ្នកផ្តើមគំនិតធ្វើទំនប់នោះ]" និងចម្លើយឆ២៥ (A25) ["ក្រោមកងពលលេខ ១៦៤។ ទំនប់នេះចាប់ផ្តើមធ្វើនៅឆ្នាំ១៩៧៧។ ទំនប់ទឹកនេះត្រូវបានធ្វើចប់ប្រហែលជាបីបួនខែក្រោយ នៅក្នុងឆ្នាំដដែល]។ ឯកសារលេខ **D54/35** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ ប្រាក់ សុខា (Prak Sokha ) ដែលស្រង់ដោយ កសចស, ត្រង់លេខ ERNជាភាសាអង់គ្លេស00977876, ត្រង់ចម្លើយឆ១៧(A17)["យើងនៅទីនោះដាំស្រូវ និងកសាងទំនប់ នៅទីនោះរហូតដល់ចុងឆ្នាំ១៩៧៧"]។ ឯកសារលេខ **D230/2.1/650c** បណ្តឹងរបស់ នាក់ យ៉ាន (Neak Yan) ត្រង់លេខ ERN ជាភាសាអង់គ្លេស 00445712 ["[អ្នកប្តឹង] ត្រូវបានចាត់តាំងអោយទៅធ្វើស្រែនៅជិតវាលយន្តហោះកងកេង នៅភូមិស្នាច់ដែង"]។ ឯកសារលេខ **D2/16** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ ទូច សឿលី (Toch Soeuli) ដែលស្រង់ដោយ កសចស, ត្រង់លេខ ERN ជាភាសាអង់គ្លេស 00629424 ត្រង់ចម្លើយឆ២១ (A21) ["ពិតមែនហើយខ្ញុំដឹងថាកម្លាំងមួយចំនួន ត្រូវបានដកយកទៅធ្វើស្រែនៅម្តុំព្រលានយន្តហោះកងកេង"]។ ឯកសារលេខ **D54/20** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ សំ សោម (Sam Soam) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយចម្លើយឆ១៤ (A14) ["ខ្ញុំបានធ្វើស្រែនៅក្នុងកងចល័តមួយ"]។

20 ឯកសារលេខ **D54/43** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ លុន សេង (Lon Seng) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយឆ១៧ (A17) ["បាទ ព្រែកចាក (Praek Chak) [មាន] ទីតាំងក្បែរវាលយន្តហោះកងកេង"]។ ឯកសារលេខ **D54/35** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ ប្រាក់ សុខា (Prak Sokha) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយឆ១៤ (A14) [" កងចល័តនោះ គឺមានអតីតយោធាកងពល១៦៤ ដែលចាត់ទុកថា សមាសភាពមិនល្អ កងចល័តនោះគឺឋិតនៅក្រោមការគ្រប់គ្រងរបស់កងពល១៦៤ដដែល។ ហើយគេបញ្ជូនអោយទៅធ្វើការនៅកន្លែងមួយដែលហៅថាភូមិព្រែកចាក (Preaek Chak Village) ឋិតនៅប្រហែល២គីឡូម៉ែត្រខាងកើតកំពង់ផែរាម"]។

21 ឯកសារលេខ **D54/35** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ ប្រាក់ សុខា (Prak Sokha) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយឆ១៧ (A17) ["គេឱ្យពួកយើងធ្វើការនៅប្របុស, ភូមិពូធឿង, នៅខាងជើងផ្លូវជាតិលេខ៤ និងទល់មុខភូមិឋិតត្រាំង។ យើងនៅទីនោះដាំស្រូវ និងកសាងនៅទីនោះទំនប់ រហូតដល់ចុងឆ្នាំ១៩៧៧"]។

22 ឯកសារលេខ **D54/41** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ អ៊ូ សារ៉ាន់ (Or Saran) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយឆ១៩ (A19) ["កងវរសេនាតូចរបស់ខ្ញុំ ត្រូវបានបញ្ជូនទៅបោះទីតាំងនៅចំការដូងរបស់ចេងហេង និងតវាលយន្តហោះកងកេង"]។ ឯកសារលេខ **D54/36** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ ប្រាក់ សុខា (Brak Sokha) ដែលស្រង់ដោយ

៩- ការដ្ឋានទាំងនេះត្រូវបានចាត់ចែងគ្រប់គ្រងដោយកងពលធំលេខ១៦៤ ដែលគ្រប់គ្រងដោយ មាស មុត ផ្ទាល់[23] ហើយដែលត្រូវបានត្រួតមើលពីលើដោយកងកម្លាំងនានាដែលត្រូវរាយការណ៍ជូនគាត់[24]។ បន្ថែមពីលើនេះ មានចំការធូរេនមួយ មានទីតាំងស្ថិតនៅត្រង់អូរត្រាវ នៅខាងត្បូងព្រលានយន្តហោះ កងកេង (ដែលទំនងជាដដែល ដូចដែលបានលើកឡើងយោងនៅក្នុងកថាខណ្ឌទី៦ និងទី១៨ នៅក្នុងឃុំរាម)ដែលត្រូវបានប្រើប្រាស់ធ្វើជាកន្លែងសម្លាប់មនុស្ស[25]។

## ទីកសាប

កសចស, ត្រង់ចម្លើយឆ២១ (A21) ["ខ្ញុំគ្រាន់តែបានឮពីចម្ការដូងដែលគេហៅ ចម្ការដូងចេង ហេង ដោយខ្ញុំបានធ្វើការនៅក្បែរៗចម្ការនោះ។ ចម្ការនោះនៅត្រង់ចុងនៃព្រលានយន្តហោះ"] ។ ឯកសារលេខ **D54/33** កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីឈ្មោះ អ៊ឹង ឈុន (Ing chhon) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយឈ១៤ (A14) ["ខ្ញុំបានស្គាល់តែចម្ការដូង"]។ ឯកសារលេខ **D54/17** កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីឈ្មោះ សយ ប៊ន (Say Born) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយឆ១៣ (A13) " ចម្ការដូងនេះ [ឋិតនៅ] ទិសនិរតីនៃព្រលានយន្តហោះកងកេង"]។ សូមមេត្តាអានខាងក្រោមនេះ កឋាខណ្ឌទី១៨ ស្ដីពីការប្រើប្រាស់ចម្ការដូងនេះជាកន្លែងសម្លាប់មនុស្ស។

23 ឯកសារលេខ **D54/17** កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីឈ្មោះ សយ ប៊ន (Say Born) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយឆ១៤-១៥ (A14-A15)។

24 ឯកសារលេខ **D54/17** កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីឈ្មោះ សាយ ប៊ន (Say Born) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយឆ១៤ (A14) ["វាជាការកន្លែងការដ្ឋានពលកម្មធម្មតារបស់កងពល១៦៤។"] និងត្រង់ចម្លើយ A15 ["ប៉ុន្តែមេបញ្ជាការកងពល ១៦៤ មាសមុត ក៏បានមកត្រួតពិនិត្យការងារនៅទីនោះដែរ"]។ ឯកសារលេខ **D2/6** កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីឈ្មោះ ញូង ជ្រោង (Nhoung Chrong) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយឆ២៤ (A24) ["វរសេនាធំលេខ២២ ជាអ្នកផ្ដើមគំនិតធ្វើទំនប់នោះ"]។ ឯកសារលេខ **D54/20** កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីឈ្មោះ សំ សោម (Sam Soam) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយឆ១៤ (A14) ["អ៊ុម ជាអ្នកមើលការងារនៅការដ្ឋានកងកេង ហើយគាត់ក៏ជាអនុមេបញ្ជាការកងពល១៦៤ ទទួលបន្ទុកភស្តុភារដែរ"]។ ឯកសារលេខ **D54/8** កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីឈ្មោះ ឌុល សុង (Dol Song) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយឆ២២ (A22) ["វរសេនាធំលេខ២២ របស់ខ្ញុំបានបោះទីតាំងនៅព្រលានយន្តហោះ កង កេង"]។ ឯកសារលេខ **D54/17** កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីឈ្មោះ សយ ប៊ន (Say Born) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយ ឆ១៣ (A13) ["កងវរសេនាតូចមួយរបស់កងវរសេនាធំ២២ ស្ថិតនៅនៅម្ខាងទៀតព្រលានយន្តហោះកងកេង"]។ សូមមេត្តាអានផងដែរ ឯកសារលេខ **D54/20** កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីឈ្មោះ សំ សោម (Sam Soam) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយឆ១៤ A14 ។ ឯកសារលេខ **D59/1/1.1/11a** ចម្លើយរបស់ ប៉ាង រ៉េត ត្រង់លេខ ERN ជាភាសាអង់គ្លេស 00974121។

25 ឯកសារលេខ **D54/90** កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីឈ្មោះ កុយ ណែន (Kuy Nen) ដែលស្រង់ដោយ កសចស ចុះថ្ងៃទី ៥ ឧសភា ២០១៤ (ជាភាសាខ្មែរតែប៉ុណ្ណោះ)។ ឯកសារលេខ **D54/91** កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីឈ្មោះ កុយ ណែន (Kuy Nen) ដែលស្រង់ដោយ កសចស ចុះថ្ងៃទី ៨ ឧសភា ២០១៤ (ជាភាសាខ្មែរតែប៉ុណ្ណោះ)។ ឯកសារលេខ **D54/127** កំណត់ហេតុស្ដីពីការបំពេញកិច្ចស៊ើបសួរ, ចុះថ្ងៃទី ១២ សីហា ២០១៤, ត្រង់លេខ ERN ជាភាសាអង់គ្លេស 01029131។

១០- កាលពីថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៤ សចសអ បានជូនដំណឹងដល់ សពអ អំពីអត្ថិភាពនៃមន្ទីរសន្តិសុខមួយ និង/ឬ គុកនៅទឹកសាប[26] ដែលដំណើរការដោយកងពលធំលេខ១៦៤ ដែលនៅជិតៗព្រលានយន្តហោះ កងកេង សម្រាប់ឃុំខ្លួន ធ្វើការអប់រំកែប្រែ និងជាយថាហេតុ សម្លាប់ពួកយោធិននៃកងពលធំលេខ១៦៤ និងជនស៊ីវិលមួយចំនួន[27]។

១១- ជាការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ទឹកសាប[28] ក្នុងនាមជាមន្ទីរសន្តិសុខរបស់កងពលធំលេខ១៦៤[29](នឹងទីតាំងរួមផ្សំគ្នាមួយចំនួនដូចជា ទីកន្លែងសំរាប់សួរចម្លើយ,

[26] ទឹក សាប (Toek Sap) ក៏ត្រូវបានគេហៅផងដែរ តាមការសរសេរអក្សរប្រកបផ្សេងខុសពីគ្នា ដូចជា Toek Sab, Tuek Sap, Tuek Sab និង Teuk Sap។

[27] ឯកសារលេខ **D102** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ, ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៤។

[28] ទឹក សាប (Toek Sap) មានពេលខ្លះ ត្រូវបានគេហៅនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីនានា ដោយយោលទៅតាមន័យត្រង់របស់វា "ការដ្ឋានទឹកសាប (fresh water site)"។ សូមមេត្តាអានផងដែរនូវ ឯកសារលេខ **D54/48** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ អែម សុន (Em Sun) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយឆ៥៣ (A53) ["តើលោកស្គាល់ តំបន់ទឹកសាបនៅវាមដែរឬទេ? ខ្ញុំស្គាល់តំបន់ហៅថា ទឹកសាប មានស្ពានទឹកសាបនៅទីនោះ គឺវាឋិតនៅតាមបណ្តោយផ្លូវជាតិលេខ៤ ទៅខាងកើតរាម"]។ ឯកសារលេខ **D54/24.1** កំណត់ហេតុរបស់សាក្សី ប៉ាក សុខ (មជ្ឈមណ្ឌលឯកសារកម្ពុជា) ត្រង់លេខ ERN ជាភាសាអង់គ្លេស 00978579-80 ["នៅពេលដែលពួកគេចាប់មនុស្ស ពួកគេបានយកអ្នកទាំងនោះទៅទឹកសាបជិតកោះកេង (កងកេង) នៅខាងកើតរាម... ចាប់ផ្តើមពីកងកេង ពួកយើងត្រូវធ្វើដំណើរសំដៅទៅទិសខាងកើតតាមផ្លូវជាតិលេខ៤ រហូតពួកយើងបានទៅដល់ត្រង់ស្ពានមួយដែលឆ្លងកាត់ស្ទឹង។ នោះគឺជាទឹកសាប... ដែលមានហេដ្ឋារចនាសម្ព័ន្ធទាំងសងខាងផ្លូវខាងជើង និងខាងត្បូងនៃផ្លូវជាតិលេខ៤..."]។ ឯកសារលេខ **D54/35.1** កំណត់ហេតុស្តាប់ចម្លើយសាក្សី ប្រាក់ សុខា (Prak Sokha) ត្រង់លេខ ERN ជាភាសាអង់គ្លេស **00971212-13** ["ពួកគេ (ខ្មែរក្រហម) បានបញ្ជូនអ្នកទាំងនោះទៅទឹកសាប ទៅកាន់កន្លែងមួយជាប់គ្នានឹងស្ពានទឹកសាប។ ខ្ញុំបានឃើញពួកគេកំពុងតែបញ្ជូនមនុស្សដែលគេចាប់ទៅទឹកសាប... ខ្ញុំ និងក្រុមនៃអង្គភាពកងចល័តរបស់ខ្ញុំបានធ្វើការនៅម្ខាងស្ទឹង ហើយជំរុំអប់រំកែប្រែនៃ [ទឹកសាប] ស្ថិតនៅម្ខាងស្ទឹងទៀត ពួកយើងអាចមើលឃើញជំរុំនោះពីខាងខ្ញុំទៅ]។ ឯកសារលេខ **D54/36** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ ប្រាក់ សុខា (Prak Sokha) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយឆ១៧ (A17) ["កងចល័តរបស់ខ្ញុំក៏បានធ្វើការនៅប៉ែកខាងត្បូងនៃផ្លូវជាតិលេខ៤ដែរ។ យើងធ្វើការនៅក្នុងតំបន់ជុំវិញព្រលានកងកេង និងតំបន់ជិតទឹកសាប"]។ ឯកសារលេខ **D54/27** កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីឈ្មោះ ប៉ាក សុខ (Pak Sok) ដែលស្រង់ដោយ កសចស, ត្រង់ចម្លើយឆ១១ (A11) ["ខ្ញុំបានឃើញមានរោងវែង២ គឺទទឹងប្រវែងប្រហែល៥ម៉ែត្រ និងបណ្តោយប្រហែល២០ម៉ែត្រ។ កន្លែងនេះនេះមិនមានរបងទេ ប៉ុន្តែមានកអ្នកយាមជាប្រចាំ"]។

[29] ឯកសារលេខ **D54/20** កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី សំ សោម, ត្រង់ចម្លើយឆ១០-១៤ (A10-A12) ["គឺឋិតក្រោមបញ្ជាការកងពល ១៦៤ របស់មាស មុត... ខ្ញុំបានដឹងពីយោធារួមការងារក្នុងអង្គភាព ។ វាជាការពិត ព្រោះសមាជិកទាំងអស់ក្នុងអង្គភាពសុទ្ធតែបានដឹងរឿងនេះ... ខ្ញុំបានដឹងថា កាលណាគេចាប់មនុស្សឬ មានអ្នកបាត់ខ្លួន គេយកអ្នកទាំងនោះទៅដាក់គុកទឹកសាបនោះ ដែលជាគុកថ្នាក់តំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ មាស មុត"]។

ធ្វើទារុណកម្ម, និងសម្លាប់)[30]ដែលស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ[31] ដែលស្របតាម៖ (ក) "ការចាប់ខ្លួនជាញឹកញាប់ និងតាមទំនើងចិត្ត និងការឲ្យធ្វើពលកម្មដោយបង្ខំ និងការបោសសំអាតនៅក្នុងរង្វង់កងពលធំលេខ១៦៤ (រួមទាំងពួកយោធិននៃភូមិភាគបូព៌ា) ដូចដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២[32]។ (ខ) ការចាប់ខ្លួន និងការសម្លាប់ជនទាំងឡាយដែលត្រូវបានគេចាត់ទុកថាជាអ្នកជាប់ពាក់ព័ន្ធនឹងរបបសាធារណរដ្ឋខ្មែរ[33]។ (គ)ការជាប់ទាក់ទងរបស់វាទៅនឹងធាតុផ្សំខាងយុត្តាធិការ, វិធីសាស្ត្រនៃការទទួលខុសត្រូវ (ដែលរួមទាំងអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម និងការចូលរួមរបស់ មាស មុត ចំពោះឧក្រិដ្ឋកម្មនេះ)។ និងអង្គការចាត់តាំង និងកំរិតនៃយន្តការសំរាប់សន្តិសុខផ្ទៃក្នុងនានារបស់កងពលធំលេខ១៦៤[34]។

## ការបញ្ជាក់បំភ្លឺស្តីពីការបោសសំអាតនានានៅក្រចេះ (តំបន់៥០៥)នៅចុងឆ្នាំ១៩៧៨

១២- សហព្រះរាជអាជ្ញាអន្តរជាតិ (សពអអ) សូមបញ្ជាក់បំភ្លឺថា ការបោសសំអាតកម្មាភិបាលយោធារបស់កងពល១១៧ និងកម្មាភិបាលស៊ីវិលនៃតំបន់៥០៥ នៅក្នុងខេត្តក្រចេះនៅចុងឆ្នាំ១៩៧៨ ដែលត្រូវបានយកមកធ្វើជាកម្មវត្ថុនៃការស្តាប់ចម្លើយសាក្សី ដែលធ្វើឡើងដោយមន្ត្រីស៊ើបអង្កេតរបស់ កសចស រហូតមកទល់បច្ចុប្បន្ននេះ ត្រូវបានដាក់បញ្ចូលនៅក្នុងវិសាលភាពនៃឧក្រិដ្ឋកម្មនានាដែលត្រូវធ្វើការស៊ើបសួរនៅក្នុងសំណុំរឿងលេខ០០៣ ធ្វើជាផ្នែកមួយនៃការចោទប្រកាន់ដែលនៅក្នុងកខាខណ្ឌទី៤៣ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ទាក់ទងនឹងកម្មាភិបាលនានាដែលត្រូវបានគេបោសសំអាត និងយកទៅមន្ទីរសន្តិសុខ ស-២១ ហើយដែលទាក់ទងទៅនឹងការ

---

30 នេះគឺរួមបញ្ចូលនូវចំការធូរេនមួយនៅក្បែរមន្ទីរសន្តិសុខទឹកសាប ដែលមនុស្សត្រូវបានគេសម្លាប់នៅទីនោះ។ នេះគឺជាចម្ការធូរេនមួយផ្សេងពីចម្ការដែលមានទីតាំងឋិតនៅភូមិរាម ឃុំរាម នៅទិសនិរតីនៃវាលយន្តហោះកងកេង។

31 ឯកសារលេខ **D102/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យទាក់ទងនឹងមន្ទីរសន្តសុខទឹកសាប, កឋាខណ្ឌទី៣ និងទី៤។

32 ឯកសារលេខ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ កឋាខណ្ឌទី ៥២ ដល់ ៥៤។

33 ឯកសារលេខ **D47/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២, ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ ត្រង់កឋាខណ្ឌទី៧។

34 ឯកសារលេខ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ កឋាខណ្ឌទី ៤២, ទី៨៦(គ)-(ឃ) និងទី៨៩។

ចោទប្រកាន់នៅក្នុងកថាខណ្ឌទី៦២ ដែលថា “មាស មុត បានអមដំណើរពលទាហាននៃកងពលធំលេខ១៦៤ ទៅកាន់ភូមិភាគព្សិសាន្ត...”។

១៣- នៅម្តុំខែវិច្ឆិកា ឆ្នាំ១៩៧៨ មាស មុត បានទៅក្រចេះជាមួយនឹងពួកយោធានៃ “កងកម្លាំងពិសេស” មកពីកងពលលេខ១៦៤[35]។ មាស មុត បានមើលខុសត្រូវលើការចាប់ខ្លួនពួកម្មាភិបាល បកក មកពីកងពលលេខ១១៧ (ដែលមានមូលដ្ឋាននៅក្រចេះ) និងតំបន់៥០៥ រួមទាំងក្រុមមួយដែលត្រូវបានគេឃើញថាត្រូវបានយកចេញដោយយន្តហោះទៅភ្នំពេញ[36]។ មាស មុត ក៏បានទទួលខុសត្រូវផងដែរលើការចាត់តាំងពួកកម្មភិបាលមកពីភូមិភាគនិរតី ដើម្បីជំនួសពួកកម្មាភិបាលដែលត្រូវបានបោសសម្អាតនៅក្រចេះ[37]។ បន្ទាប់ពីការចាប់ខ្លួន មាស មុត បានកោះប្រជុំពួកកម្មាភិបាល

---

[35] **D54/62** កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ដោយ កសចស, ត្រង់ A22, 24, 26-27 [ឆ.២៦៖ “ខ្ញុំបានឃើញតែកងកម្លាំងទ័ពរបស់ [មាស មុត] បានបោះទីតាំងនៅភូមិគោលាប់ ក្នុងខេត្តក្រចេះ។ កងវរសេនាធំរបស់ ភាព គឺជាកងកម្លាំងពិសេសរបស់ មាស មុត។ ស៖ តើនៅពេលណាដែលកងវរសេនាធំជើងទឹករបស់ ភាព ទៅដល់ខេត្រក្រចេះ? ឆ.២៧៖ ប្រហែលចុងខែវិច្ឆិកាឆ្នាំ១៩៧៨”។ **D54/60.2** កិច្ចសម្ភាសន៍ ម៉ឹង វេត ដោយ DC-Cam, ត្រង់ EN 00992990 [“ឆ្នាំ៧៨នេះ បានគាត់ទៅក្រចេះបានតែបន្តិចហ្នឹង ទៅក្រោយចាប់អ៊ំ វន វ៉េត ហើយទេ”។ **D54/23** កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ដោយ កសចស, ត្រង់ A8-9។ **D4.1.810** កំណត់ហេតុស្តាប់ចម្លើយ សេង សឿន ដោយ កសចស, ត្រង់ A27-A31។ **D54/50** កំណត់ហេតុស្តាប់ចម្លើយ មាស រឿន ដោយ កសចស, ត្រង់ A4-7, 9 [ដោយបានរៀបរាប់ពីការដាក់ពង្រាយកងកម្លាំងរបស់កងពលលេខ១៦៤ ទៅខេត្តក្រចេះ នឹងព្រឹត្តិការណ៍នានាជាមួយនឹងកងពលលេខ១ នៅខែវិច្ឆិកា ឬខែធ្នូ ឆ្នាំ១៩៧៨]។ **D1.3.13.3** ហឺន ផោប ហៅ ភាព (Heuan Phoap alias Pheap), សេចក្តីថ្លែងដោយ SOAS, ៩ កញ្ញា ២០០៥, ត្រង់ EN 00207786 [“រ៉េន (Raen) បានទៅភូមិភាគព្សិសានក្រោយ ម៉េត និង **មុត**, ទៅជំនួស រឿន (Reuan) ដែលត្រូវបានបញ្ជូនទៅភ្នំពេញ។ រ៉េន (Raen) បានដឹកនាំការប្រយុទ្ធចូលទៅក្នុងប្រទេសវៀតណាម...”]។

[36] **D54/60.2** កិច្ចសម្ភាសន៍ ម៉ឹង វេត ដោយ DC-Cam, ត្រង់ EN 00992993-95 [ដោយបានរៀបរាប់ពីការចាប់ពួកកម្មភិបាលមួយក្រុមចំនួន១១នាក់ ដាក់ក្នុងយន្តហោះទៅភ្នំពេញ, រួមទាំងពូរបស់គាត់ឈ្មោះ ឈុំ ចិន ហៅ ភ័ណ្ឌ (លេខាស្រុកស្នួល), ឈ្មោះ រ៉ុំ ប្រធានកងពលលេខ១១៧ និងឈ្មោះ ផាន (Phan) មេបញ្ជាការកងវរសេនាធំ]។ **D54/62** កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ដោយ កសចស, ត្រង់ A24, 29-30, 32-33, 38-39 [ដោយបានរៀបរាប់ពីសមាសភាពរបស់ក្រុម១១នាក់ ដែលបានបញ្ជូនទៅភ្នំពេញដើម្បីប្រជុំ, អង្គហេតុពិតដែលលិខិតអញ្ជើញអ្នកទាំងនោះទៅភ្នំពេញគឺត្រូវបានប្រគល់ឱ្យដោយនីរសាររបស់ មាស មុត ហើយក្រោយមកអ្នកទាំងនោះត្រូវបានសម្លាប់ចោលនៅស-២១]។ **D54/63** កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ដោយ កសចស, ត្រង់ A2-3។ **D4.1.810** កំណត់ហេតុស្តាប់ចម្លើយ សេង សឿន ដោយ កសចស, ត្រង់ A35-A36 [ដោយបានឃើញឈ្មោះ យេង លេខាស្រុកក្រចេះ និងឈ្មោះ ភាន់ លេខាស្រុកស្នួល “នៅពេលពួកគាត់ឡើងយន្តហោះ” ហើយត្រូវបានគេបញ្ជូនទៅទីក្រុងភ្នំពេញដើម្បីសម្លាប់ដែរ, និងត្រូវបានប្រាប់ដោយ មាស មុត ថា “មនុស្សទាំងនោះត្រូវបានគេយកទៅកម្ទេច”]។

[37] **D4.1.810** កំណត់ហេតុស្តាប់ចម្លើយ សេង សឿន ដោយ កសចស, ត្រង់ A27 [“លិខិតនោះមានបញ្ជាក់ថា មាស មុត គឺជាអ្នកទទួលខុសត្រូវចាត់ចែងការងារឱ្យមនុស្សខាងលើ”]។ **D54/62** កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ដោយ កសចស, ត្រង់ A35 [“ឆ.35៖ មនុស្សទាំង៥នាក់នេះ [សៅ ផុន, ឡេង, ប៉ក់, សេង សឿន, សាន និង ខុន] មកពីភ្នំពេញតាមយន្តហោះក្នុងពេលជាមួយគ្នានឹងការបញ្ជូនមនុស្ស ១១ នាក់ត្រឡប់ទៅភ្នំពេញវិញ”។

កងពលលេខ១១៧ និងតំបន់៥០៥ ដែលនៅសេសសល់ ហើយបានប្រកាសថាខ្លួនបានសម្រេចដកមេដឹកនាំពួកគេចេញពីព្រោះអ្នកទាំងនោះគឺជាពួកក្បត់ "មិនដាច់ខាតវ៉ៃនឹងយួន"[38]។ ដូចដែលបញ្ជីឈ្មោះអ្នកទោសនៅស-២១ បានបញ្ជាក់ស្រាប់ហើយថាពួកកម្មាភិបាលកងពលលេខ ១១៧ និងតំបន់៥០៥ ដែលត្រូវបានបញ្ជូនទៅស-២១ នៅចុងឆ្នាំ១៩៧៨ រួមមានៈ (១) លេខាកងពលលេខ១១៧ ឃុន រុំ (ដែលបានចូលទៅ "គុកពិសេស" ស-២១ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨), (២) អនុលេខា រ័ត្ន លាង និង (៣) នាយការិយាល័យកងពល ស្វាយ ណូញ (ទាំងពីរនាក់នេះបានចូលនៅថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៧៨)[39], (៤) លេខាតំបន់៥០៥ មាស មឿន (ថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨) និង (៥) អនុលេខា ឈឹម ខុន (ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨)[40], (៦) លេខាស្រុកស្នួល ឃុំ ចិន *ហៅ* ភ័ន និង (៧) លេខាស្រុកក្រចេះ ហួន យ៉េង (ថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៨)[41], (៨) ពួកមេបញ្ជាការវរសេនាធំលេខ១១៧ កិល សុផន *ហៅ* ផន (ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៨), (៩) ចាប ហឿន និង (១០) ប៊ី រ៉ី (ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៨)[42], និង (១១) ពួកកម្មាភិបាលតំបន់៥០៥ ចំនួន២២នាក់ផ្សេងទៀត រួមមានប្រធានឃុំ និងប្រធានសហករណ៍នានាដែលបានចូលទៅស-២១ ជាមួយគ្នានៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៧៨[43]។

---

[38] **D54/63** កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ដោយ កសចស, ត្រង់ A2 ["មាស មុត បានខឹង ដោយគាត់និយាយថា ពួកយើងមិនដាច់ខាតវ៉ៃនឹងយួនទេ។ ដោយសារតែព្រឹត្តិការណ៍ទាំងនេះបានជា តាមុត គាត់ឈប់ជឿលើថ្នាក់ដឹកនាំកងពល ហើយដកអ្នក១១នាក់នោះចេញ"]។ **D54/60.2** កិច្ចសម្ភាសន៍ ម៉ឹង វេត ដោយ DC-Cam, ត្រង់ EN 00992993-94 & 00993000 [ការប្រជុំដែល មាស មុត "ប្រកាសថាពួកមេហ្វែងក្បត់អស់ហើយ" ហើយបានចាត់តាំងពួកកម្មាភិបាល "ហ្វែងទៅវាយយួន"]។ **D54/62** កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ដោយ កសចស, ត្រង់ A30 ["មាស មុត ប្រាប់ថា "ពួកមេៗរបស់ពួកយើងក្បត់អស់ហើយ។ ដូច្នេះពួកអាធំៗទៅវ៉ៃយួន ចំណែកឯពួកអាតូចៗក្មេងៗ ដឹកសម្ភារៈទៅស្ទឹងត្រែង"]។

[39] **D1.3.28.137**, បញ្ជីឈ្មោះអ្នកទោសនៅស-២១, ១៥ ធ្នូ ១៩៧៨, ត្រង់ EN 00758336-37 (ឃុន រុំ ត្រង់លេខ១៨, រ័ត្ន លាង ត្រង់លេខ ៨, ស្វាយ ណូញ ត្រង់លេខ៦)។ **D1.3.28.138**, បញ្ជីឈ្មោះអ្នកទោសនៅស-២១, ១៥ ធ្នូ ១៩៧៨, ត្រង់ EN 00789491-92 (ឃុន រុំ ត្រង់លេខ១៨, រ័ត្ន លាង ត្រង់លេខ៨, ស្វាយ ណូញ ត្រង់លេខ៦)។ **D1.3.28.138**, បញ្ជីឈ្មោះអ្នកទោសនៅស-២១, ១៥ ធ្នូ ១៩៧៨, ត្រង់ EN 00789491-92 (ឃុន រុំ ត្រង់លេខ២០, រ័ត្ន លាង ត្រង់លេខ៩ ស្វាយ ណូញ ត្រង់លេខ៧)។

[40] **D1.3.28.137**, បញ្ជីឈ្មោះអ្នកទោសនៅស-២១, ១៥ ធ្នូ ១៩៧៨, ត្រង់ EN 00758336-37 (មាស មឿន ត្រង់លេខ១៥, ឈឹម ខុន ត្រង់លេខ៤)។ **D1.3.28.138**, បញ្ជីឈ្មោះអ្នកទោសនៅស-២១, ១៥ ធ្នូ ១៩៧៨, ត្រង់ EN 00789491-92 (មាស មឿន ត្រង់លេខ១៧, ឈឹម ខុន ត្រង់លេខ៤)។

[41] **D1.3.28.146**, បញ្ជីឈ្មោះអ្នកទោសនៅស-២១, ១៦ ធ្នូ ១៩៧៨, ត្រង់ EN 00789507 (ត្រង់លេខ១០-១១)។

[42] **D1.3.28.141**, បញ្ជីឈ្មោះអ្នកទោសនៅស-២១, ធ្នូ ១៩៧៨, ត្រង់ EN 00789707-08 (ត្រង់លេខ២-៣, ៥)។ **D1.3.28.146**, បញ្ជីឈ្មោះអ្នកទោសនៅស-២១, ១៦ ធ្នូ ១៩៧៨, ត្រង់ EN 00789505 (ត្រង់លេខ២-៣ & ៥)។

[43] **D1.3.28.146**, បញ្ជីឈ្មោះអ្នកទោសនៅស-២១, ១៦ ធ្នូ ១៩៧៨, ត្រង់ EN 00789508-10។

១៤- សពអ សូមបញ្ជាក់ថា នៅឆ្នាំ១៩៧៨ មាស មុត ត្រូវបានចាត់តាំងឱ្យធ្វើការនៅអគ្គសេនាធិការដ្ឋាន កងទ័ព នៅភ្នំពេញ ដោយហេតុថាគាត់ត្រូវបានតម្លើងឋានន្តរសក្តិជាអគ្គសេនាធិការរង ដែលមាន សុន សេន (លេខា) និង ស៊ូ ម៉េត (សមាជិក) ជាសមាជិកដទៃទៀតនៃគណៈកម្មាធិការរបស់អគ្គសេនាធិការ[44]។ នៅក្នុងអំឡុងពេលដែល មាស មុត ជាអនុលេខារបស់អគ្គសេនាធិការ មានសមាជិកនៃគណៈកម្មាធិការនោះជាច្រើន ត្រូវបានចាប់បញ្ជូនចូលទៅ ស-២១[45]។

## សេចក្តីបញ្ជាក់ពាក់ព័ន្ធនឹងតំបន់រាម

១៥- ដីកាបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ដែលបានថែងពីសារៈសំខាន់នៃរាម នៅក្នុងកថាខណ្ឌទី៨២ និងទី៨៦(ក) ថ្លែងថា កងពលលេខ១៦៤ នៃកងទ័ពបដិវត្តកម្ពុជា មានមូលដ្ឋាននៅកំពង់សោម និងនៅរាម ហើយ មាស មុត ក្នុងឋានៈជាលេខាកងពលលេខ១៦៤ បានទទួលខុសត្រូវការពារឆ្នេរ

---

[44] **D54/62**, កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ដោយ កសចស, ១៣ កុម្ភៈ ២០១៤, ត្រង់ A22 ["មាស មុត ជាអគ្គសេនាធិការរងរបស់កងទ័ព មានន័យថា អនុរបស់ សុន សេន។ នៅពេលយួនវ៉ៃបុកមកលើយើងនៅតាមព្រំដែន មាស មុត ត្រូវតែទៅត្រួតពិនិត្យស្ថានការណ៍នៅសមរភូមិមុខ"] និង A23 ["សុន សេន ជាមេបញ្ជាការអគ្គសេនាធិការ (...)។ មាស មុត ជាអនុរបស់ សុន សេន ទទួលខុសត្រូវខាងជើងទឹក។ ស៊ូ ម៉េត ជាសមាជិកទទួលខុសត្រូវខាងជើងអាកាស"។ **D59/1/1.8a**, កិច្ចសម្ភាសន៍ ព្រំ សារ៉ាត់ ដោយ DC-Cam, ១៩ ឧសភា ២០០៧, ត្រង់ EN 00974225-27 [នៅម្តុំខែកញ្ញា ឆ្នាំ១៩៧៨ មាស មុត បានទៅភ្នំពេញ តមកទៀតឈ្មោះ សេង និងឈ្មោះ សារឿន ទទួលគ្រប់គ្រងកងពលលេខ១៦៤ ជាបណ្តោះអាសន្ន។ មាស មុត ក៏បានទៅ មេមត់ ផងដែរជាកន្លែងដែលគាត់ "ជំនួសឱ្យតា សុន សេន"។ មាស មុត ជាអគ្គមេបញ្ជាការរងសេនាធិការ ដែលទើបនឹងឡើងនៅចុងឆ្នាំ១៩៧៨។ **D54/100**, កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ដោយ កសចស (ភាសាខ្មែរប៉ុណ្ណោះ), [មាស មុត ជាមេបញ្ជាការកងពលលេខ១៦៤ រហូតដល់គាត់ផ្លាស់ទៅសេនាធិការនៅចុងឆ្នាំ១៩៧៨]។ **D59/1/1.11a**, កិច្ចសម្ភាសន៍ ហៀង រ៉េត ដោយ DC-Cam, ២០ មេសា ២០០៧, ត្រង់ EN 00974119-20 [មាស មុតត្រូវបានផ្លាស់ទៅភ្នំពេញធ្វើជាអគ្គសេនាធិការរង ទទួលខុសត្រូវខាងជើងទឹកបានជាងមួយឆ្នាំមុននឹងពួកយួនចូលមកដល់ ប៉ុន្តែនៅតែគ្រប់គ្រងលើកងពលលេខ១៦៤ដដែល]។ **D54/28.1**, កិច្ចសម្ភាសន៍ លាត ឡូន *ហៅ* ណាំ ឡូន ដោយ DC-Cam, ២៥ មេសា ២០០៧, ត្រង់ EN 00996685 [តាមុត នៅក្រោម សុន សេន នៅអគ្គសេនាធិការ និងនៅភ្នំពេញជាញឹកញាប់]។

[45] **D1.3.28.137**, បញ្ជីឈ្មោះអ្នកទោសនៅស-២១, ១៥ ធ្នូ ១៩៧៨, ត្រង់ EN 00758336 (កម្មាភិបាលជាន់ខ្ពស់២នាក់ បានចូលគុកពិសេសនៅស-២១ នៅថ្ងៃទី៩ ធ្នូ ១៩៧៨៖ ស្រី ង៉ែត *ហៅ* រឿង ជាសមាជិកគណៈសេនាធិការ និងជាសមាជិកគណៈភស្តុភារ សេនាធិការ)។ **D1.3.28.146**, បញ្ជីឈ្មោះអ្នកទោសនៅស-២១, ១៦ ធ្នូ ១៩៧៨, ត្រង់ EN 00789501-03 (សមាជិកសេនាធិការ ២០នាក់ បានចូលស-២១ នៅចន្លោះថ្ងៃទី៥ និងទី២៥ ធ្នូ ១៩៧៨)។ **D1.3.28.141**, បញ្ជីឈ្មោះអ្នកទោសនៅស-២១, ធ្នូ ១៩៧៨, ត្រង់ EN 00789704 (កម្មាភិបាលសេនាធិការ១០នាក់ ចូលស-២១ នៅថ្ងៃទី៥-១០ ធ្នូ ១៩៧៨)។ **D4.1.157**, បញ្ជីឈ្មោះអ្នកទោសនៅស-២១, កក្កដា-ធ្នូ ១៩៧៨, ត្រង់ EN 00185219-21 (សមាជិកសេនាធិការ ២៩នាក់ ភាគច្រើនបានចូលស-២១ នៅចន្លោះកក្កដា និងធ្នូ ១៩៧៨)។

សមុទ្រកម្ពុជា រួមទាំងទីប្រជុំជនរាមផង[46]។ កថាខណ្ឌទី៥៨ ដល់ទី៦១ នៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរនេះ ក៏បានពន្យល់ផងដែរអំពីតួនាទីគន្លឹះដែលបានបំពេញដោយកងទ័ពជើងទឹកនៃកម្ពុជាប្រជាធិបតេយ្យ នៅក្នុងការចាប់ខ្លួននៅឯសមុទ្រចំពោះពួកអ្នកនេសាទវៀតណាម និងថៃ ឬពួកជនបរទេសផ្សេងៗទៀត និងពីវាសនារបស់ពួកទាំងនោះនៅពេលក្រោយទៀត (ពលកម្មដោយបង្ខំ ការប្រហារជីវិត ឬការបញ្ជូនទៅកាន់ ស-២១)។

១៦- សពអ សូមបញ្ជាក់ថា កំពង់ផែរាម/មូលដ្ឋានកងទ័ពជើងទឹក, ទីកន្លែងពលកម្មដោយបង្ខំ (សហករណ៍) និងទីកន្លែងសម្លាប់មនុស្សនានា (រួមទាំងចំការធូរេនដែលបានពិភាក្សានៅខាងលើ) ដែលមានទីតាំងនៅឃុំរាម ស្រុកព្រៃនប់ ហើយដែលត្រូវបានប្រតិបត្តិការដោយកងពលលេខ១៦៤ ក្រោមអំណាចរបស់ មាស មុត គឺសុទ្ធតែឋិតនៅក្រោមវិសាលភាពនៃឧក្រិដ្ឋកម្មទាំងឡាយ ដែលត្រូវស៊ើបសួរនៅក្នុងសំណុំរឿងលេខ០០៣។

១៧- មូលដ្ឋានកងទ័ពជើងទឹករាម គឺជាផែកប៉ាល់ដ៏សំខាន់បំផុតរបស់កងពលលេខ១៦៤[47] ហើយជាលទ្ធផលត្រូវបានតភ្ជាប់ទៅសកម្មភាពនានារបស់កងទ័ពបដិវត្តកម្ពុជានៅលើកោះនានា នៃកម្ពុជាប្រជាធិបតេយ្យ ហើយដោយឡែកគឺភ្ជាប់ទៅនឹងការចាប់ខ្លួន ការឃុំឃាំង ឬការប្រហារជីវិតពួកជនបរទេសដែលបានចាប់ខ្លួននៅក្នុងដែនទឹកនៃកម្ពុជាប្រជាធិបតេយ្យ។ រាមត្រូវបានប្រើប្រាស់ជាកំពង់ផែសម្រាប់កប៉ាល់យោធា, ជាកន្លែងសម្រាប់ថែរក្សា និងជួសជុល, ដើម្បីដឹកចម្លងទំនិញទៅកាន់កោះនានា, ជាឃ្លាំងមីន និងដាក់គ្រាប់រំសេវ[48]។ កំពង់ផែរាមត្រូវបានដាក់នៅក្រោមអំណាច

---

[46] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, កថាខណ្ឌទី៤២, ៨៦(ក)។ **D47/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២, ២១ មិថុនា ២០១២, កថាខណ្ឌទី៨។

[47] **D1.3.13.11**, កំណត់ហេតុស្តាប់ចម្លើយ សៀង Sieng ដោយ កសព, ត្រង់ EN 00217565 ["មូលដ្ឋានខាងជើងទឹកធំនៅរាម ហើយកន្លែងគ្រប់គ្រងកងពលនៅទីនោះ"]។ **D1.3.13.13** កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ដោយ កសព, ត្រង់ EN 00217572 ["មានផែ៤(បួន)គឺ៖ រាម អូរឈើទាល កោះរ៉ុង និង ស្ទឹងហាវ។ កងនាវាបើកបរទៅ-មក មិននៅមួយកន្លែងទេ"]។ **D54/17** កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ដោយ កសចស, ត្រង់ A13 ["ទីតាំងនៃមូលដ្ឋានកងនាវាចរនៅរាមរបស់កម្ពុជាប្រជាធិបតេយ្យ គឺនៅត្រង់កន្លែងមូលដ្ឋានកងនាវាចរណ៍កម្ពុជាបច្ចុប្បន្ន (មិនអាចចូលទៅមើលបាន)"]។

[48] **D59/1/1.8a** កិច្ចសម្ភាសន៍ ព្រុំ សារ៉ាត់ ដោយ DC-Cam, ត្រង់ EN 0094215 ["កប៉ាល់ចេញចូលធម្មតា ជួសជុលរប៉េះរប៉ោះ... ដានី៖ កន្លែងជួសជុល? សារ៉ាត់៖ បាទ!... កន្លែងរាមប្រើប្រាស់ជាកន្លែងផ្ទុកមីន អាមីនបាញ់គ្រាប់បណ្តែត"]។ **D2/9** កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ដោយ កសចស, ត្រង់ A57 ["យើងពុំដែលចូលចតនៅកំពង់ផែរាមទេ ប៉ុន្តែយើងចូលចាក់ប្រេងនាវា រួចហើយនៅក្នុងឆ្នាំ១៩៧៨ ពេលដែលស្ថានការណ៍ផ្លាស់ប្តូរមានបញ្ហាឲ្យយើងចូលទៅដាក់គ្រាប់នៅទីនោះ ទើបយើងចូល ពីព្រោះកន្លែងនោះជា ឃ្លាំងដាក់គ្រាប់ធំៗ"]។

ផ្ទាល់របស់កងវរសេនាធំលេខ១៤០ (កងទ័ពជើងទឹក)[49]។ កប៉ាល់នាវារបស់កងពលលេខ១៦៤ បានចាប់ពួកអ្នកនេសាទបរទេស/ពួកជនភៀសខ្លួន/ពួកនាវិក ដែលក្រោយមក ត្រូវបានបញ្ជូនទៅកាន់មូលដ្ឋានរាម[50] ឬទៅកាន់បញ្ជាការដ្ឋានកងពលលេខ១៦៤[51]។ ពួកអ្នកនេសាទថៃ និងពួកបរទេសមួយចំនួនដែលបានចាប់ខ្លួន ត្រូវបានបង្ខំឱ្យធ្វើការនៅរាម ឬនៅតាមបណ្តាកោះនានា[52]

---

**D1.3.13.13** កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ដោយ កសព, ត្រង់ EN 00217574 ["ពួកគេដាក់បញ្ចូលគ្រាប់ជាញឹកញាប់នៅរាម..."]។ **D59/1/1.12** កិច្ចសម្ភាសន៍ ណុប ហាល់ ដោយ DC-Cam ត្រង់ EN 00968382 ["ផែរាមហ្នឹងសម្រាប់យើងដឹកឥវ៉ាន់មកកោះ ដឹកសំណង់ដឹកឥដ្ឋអីៗ ដឹកស្បៀងដឹកអីៗឱ្យកងនៅកោះ"។ **D59/1/1.9a** កិច្ចសម្ភាសន៍ ឡាយ ប៊ុនហាក់ ដោយ DC-Cam ត្រង់ EN 00963728 ["អាហ្នឹងសម្រាប់នាវាចរសម្រាប់កប៉ាល់ពេលចប់បេសកកម្ម យើងទៅចតនាវាដឹកអ្នកដំណើរ"]។

[49] **D54/8** កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ដោយ កសចស, ត្រង់ A22-23 ["ក្រោយមកប្រហែលដើមឆ្នាំ១៩៧៦ ខ្ញុំបានចេញពីវរសេនាធំ២២ ទៅនៅក្នុងវរសេនាធំ១៤០ នៅរាម"។ […]។ "ព្រលានយន្តហោះកងកេង គឺជាមូលដ្ឋានកងវរសេនាធំ២២។ ចំណែកវរសេនាតូចរបស់ខ្ញុំ ពេលនោះត្រូវបានបញ្ជូនទៅកងវរសេនាធំ១៤០ នៅរាម"]។

[50] **D1.3.13.13** កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ដោយ កសព, ត្រង់ EN 00217575 ["ទោះបីជាត្រូវបានប្រើប្រាស់សម្រាប់ល្បបយកការ និងធ្វើចារកម្មប្រមូលកប៉ាល់ ក៏ជួនកាលពួកគេបានចាប់ពួកអ្នកនេសាទថៃដែរ"]។ **D54/24.1** កិច្ចសម្ភាសន៍ ប៉ាក សុខ ដោយ DC-Cam (សំណៅកែតម្រូវ) ត្រង់ EN 00978578 ["មានចាប់ទូកថៃ អា៥០០សេះ អា៤០០សេះ អា៨០០សេះ។... ចាប់យកមកដាក់លើកោះ។... មនុស្សបញ្ជូនយកមកដីគោកខាងរាមនេះ។... ខ្លះថាបញ្ជូនមកដីគោកហើយគេបញ្ជូនមកកោះកុងវិញ។... [បាទ, គេ]ចង បើជាយួនគេ[ពួកខ្មែរក្រហម]បញ្ជាមកឱ្យវ៉ៃចោល"], ត្រង់ 00978577 [ពិភាក្សាអំពីការចាប់ខ្លួនជនជាតិអាមេរិកកាំងម្នាក់ អាយុ ២៥ឆ្នាំ នៅដើមឆ្នាំ១៩៧៦ បញ្ជូនមករាម ហើយឱ្យទៅខាងកងពលលេខ១៦៤]។ **D54/25** កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ដោយ កសចស, ត្រង់ A13 ["ការចាប់បានទូកនេសាទថៃ កម្លាំងម៉ាស៊ីន ៤០០សេះ គឺក្នុងខែ៦ ឆ្នាំ១៩៧៦។ (...) អ្នកនេសាទថៃទាំងអស់នោះ ត្រូវ ដឹកជញ្ជូនទៅរាម", A16 ["ពួកគេត្រូវបានបញ្ជូនទៅរាម ហើយក្រោយមកបញ្ជូនឱ្យទៅធ្វើការនៅលើកោះតាគាវជាមួយពួកមុនដែរ ព្រោះខ្ញុំបានជួបពួកគេនៅពេលដែលខ្ញុំទៅធ្វើការនៅទីនោះ"]។

[51] រឿងនេះអាចទាញការសន្និដ្ឋានចេញពីការអនុវត្តដែលបានប្រើប្រាស់នៅតាមមូលដ្ឋានផ្សេងៗទៀតនៃកងវរសេនាធំជើងទឹក ដូចជានៅអូរឈើទាល និងកោះតាង ជាដើម៖ **D54/79** កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល់ ដោយ កសចស, ត្រង់ A3 (EN 00992450) ["ក្នុងករណីដែលចាប់ទូក និងមនុស្សនៅលើទូក គឺទាំងមនុស្ស ទាំងទូកត្រូវបានបញ្ជូនដោយនាវារបស់កងវរសេនាធំ១៤០ ទៅកំពង់សោម ឬទីតាំងកោះណាមួយក្នុងរយៈពេលខ្លី មុននឹងបញ្ជូនទៅកំពង់សោម"], A8 ["កម្លាំងដែលមកទទួលពួកវៀតណាមទាំងនោះ[នៅផែកំពង់សោម - អូរឈើទាល] គឺមកពីមន្ទីរក្នុងរបស់កងពលលេខ១៦៤"]។ **D2/15** កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី *ហៅ* សឿ ទូច ដោយ កសចស, ត្រង់ A9 ["នៅក្នុងកថាខណ្ឌទី៣៥ ក្នុងឃ្លាទី១ ដែលសរសេរថា "សាក្សីបាននិយាយថា គាត់បានចាប់ប្រជាជនវៀតណាមជាច្រើន រួចហើយបញ្ជូនទៅឱ្យខាងកងពល"។ សាក្សីបានធ្វើការកែតម្រូវថា "គាត់មិនមែនជាអ្នកចាប់ទេ អ្នកចាប់គឺនៅក្នុងអង្គភាពផ្សេង គាត់មិនដឹងជាអង្គភាពលេខប៉ុន្មានទេ ប៉ុន្តែដោយគាត់នៅនឹងផែ[អូរឈើទាល] ទើបគាត់ឃើញគេចាប់យកមកកន្លែងផែហ្នឹងដើម្បីបញ្ជូនឡើង"]។

[52] **D54/24.1** កិច្ចសម្ភាសន៍ ប៉ាក សុខ ដោយ DC-Cam (សំណៅកែតម្រូវ) ត្រង់ EN 00978574-75 ["បាទ! រាមនឹងយក[ពួកអ្នកនេសាទថៃដែលចាប់បាននៅសមុទ្រ]មក មិនមែនយកមកសម្លាប់ទេ ឱ្យបាយហូបធម្មតាយើងប្រើ។... គេយកមកខ្លះឱ្យលើកទំនប់អីចឹង ខ្ញុំមកឃើញដែលតើ"]។ **D54/25** កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ដោយ កសចស, ត្រង់ A13 ["ការចាប់បានទូកនេសាទថៃ កម្លាំងម៉ាស៊ីន ៤០០សេះ គឺក្នុងខែ៦ ឆ្នាំ ១៩៧៦។ (...) អ្នកនេសាទថៃទាំងអស់នោះ ត្រូវដឹកជញ្ជូនទៅរាម។ ខ្ញុំបានជួបពួកនេសាទទាំងនោះនៅលើកោះតាគាវប្រហែល៦-៧ខែក្រោយមក", A16 ["ពួកគេត្រូវបានបញ្ជូនទៅរាម ហើយក្រោយមកបញ្ជូនឱ្យទៅធ្វើការនៅលើកោះតាគាវជាមួយពួកមុនដែរ ព្រោះខ្ញុំបានជួបពួកគេ នៅពេលដែលខ្ញុំទៅធ្វើការនៅទីនោះ"]។

ខណៈដែលអ្នកដទៃទៀត ជាពិសេសពួកវៀតណាម ត្រូវបានប្រហារជីវិតតាមបញ្ជារបស់កងពលលេខ១៦៤[53]។ ភស្តុតាងក៏បានលើកស្នើឡើងផងដែរថា ពួកអ្នកដែលគេសង្ស័យ ថាជាភ្នាក់ងារចារកម្ម ឬជាយោធាវៀតណាម ត្រូវបានបញ្ជូនទៅកាន់ស-២១[54]។ កប៉ាល់ថៃ និងកប៉ាល់វៀតណាមដែលត្រូវចាប់បាន ត្រូវបានរក្សាទុកនៅកំពង់ផែរាម[55]។

---

[53] **D54/24.1** កិច្ចសម្ភាសន៍ ប៉ាក សុខ ដោយ DC-Cam (ភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ដោយ កសចស) ត្រង់ EN 00978578 ["មានចាប់ទូកថៃ អា៥០០សេះ អា៤០០សេះ អា៨០០សេះ។... ចាប់យកមកដាក់លើកោះ។... មនុស្សបញ្ជូនយកមកដីគោកខាងរាមនេះ។... ខ្លះថាបញ្ជូនមកដីគោកហើយគេបញ្ជូនមកកោះកុងវិញ។... [បាទ, គេ]ចង បើជាយួន គេ[ពួកខ្មែរក្រហម]បញ្ជាមកឱ្យវៃចោល"]។ **D54/23** កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ដោយ កសចស, ត្រង់ A25 ["រួចហើយទើបកងពលបញ្ជាតាមខ្សែរយៈត្រឡប់ចុះមកវិញ ថាតើយើងគួរធ្វើយ៉ាងម៉េចជាមួយទូក កប៉ាល់ ហើយនិងមនុស្សដែលយើងចាប់បាន។... ជាទូទៅ កាលណាចាប់បានតិចជាង២០នាក់ គឺបញ្ជាឱ្យសម្លាប់នៅនឹងកន្លែង បើចាប់បានច្រើនជាង២០នាក់ ត្រូវបញ្ជូនទៅអូរឈើទាល។ តាមខ្ញុំដឹង អ្នកដែលបញ្ជូនមកដីគោកទាំងនោះក្រោយមកត្រូវគេសម្លាប់ចោលដែរ។ ពួកអ្នកដែលចាប់បាន ហើយបញ្ជូនទៅកំពង់សោម ត្រូវគេសម្លាប់ ហើយកប់ចោលនៅក្រោមដើមទុរេនដើមដូង"]។ **D1.3.13.8** កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សារិន ដោយ កសព, ត្រង់ EN 00217561-62 ["សាក្សីបានធ្វើការនៅមូលដ្ឋានជើងទឹកប្រហែលមួយសប្តាហ៍នៅឆ្នាំ១៩៧៦ ហើយក្នុងពេលនោះគាត់បានឃើញពួកអ្នកនេសាទថៃពីរក្រុម (ចំនួនពី១៥-២០នាក់ក្នុងមួយលើកៗ យកទៅដាក់ក្នុងអាគារមួយក្នុងបន្ទាយនៅមូលដ្ឋានទ័ព។ ពួកនោះត្រូវបានចងពេលដែលយកទៅកាន់អាគារនោះ។ ពួកអ្នកនេសាទទាំងនេះត្រូវបានចាប់នៅឆ្ងាយពីកោះតាង និងកោះរង់ (Tang and Rong Islands)។ គាត់ជឿជាក់ថាអ្នកនេសាទទាំងនេះត្រូវបានសម្លាប់ចោល ពីព្រោះបានចាប់ត្រីនៅក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ)"]។

[54] **D54/23** កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ដោយ កសចស, ត្រង់ A29 ["ប្រសិនបើអ្នកដែលត្រូវបានចាប់ខ្លួននោះជាទាហានវៀតណាម យើងត្រូវតែបញ្ជូនពួកនោះទៅដីគោក បន្ទាប់មកគេនឹងធ្វើការចាក់ផ្សាយចម្លើយសារភាពរបស់ទាហានវៀតណាមនៅក្នុងវិទ្យុជាតិមុនពេលគេសម្លាប់"]។ **D59/1/1.8a** កិច្ចសម្ភាសន៍ ព្រំ សារ៉ាត់ ដោយ DC-Cam ត្រង់ EN 0094216 និង 0094222 ["ពួកគេអាចចូលទៅរាម ឬចូលទៅកំពង់សោម។...នៅពេលហ្នឹងគឺថាដាច់ពីគ្នាយើង ដូចមិនអាចមើលឃើញគ្រប់ពេលណា ពេលដែលយើងឃើញៗ ប៉ុនដល់ចេញផុតៗ"]។ **D1.3.1.13**, ចម្លើយសារភាពរបស់ វិញមិញចូវ នៅស-២១, ៣ មេសា ១៩៧៨ [ទាហានជើងទឹកវៀតណាមដែលគេចោទប្រកាន់ ត្រូវបានចាប់ខ្លួននៅយប់ថ្ងៃទី១៣ មីនា ១៩៧៨ នៅកោះមួយក្នុងប្រទេសកម្ពុជា។ ភ្ជាប់ទៅនឹងចម្លើយសារភាពនេះ គឺជាបញ្ជីឈ្មោះពួកអ្នកទោសវៀតណាមចំនួន១៨នាក់ មានអាយុចន្លោះពី ១៧ ទៅ ៥៨ - មានទាំងទាហាន ទាំងជនស៊ីវិល ត្រូវបានចាប់ខ្លួននៅចន្លោះខែមករា និងខែឧសភា ឆ្នាំ១៩៧៨។ ប្រាំពីរនាក់ក្នុងចំណោមអ្នកទោសវៀតណាមដែលមានឈ្មោះក្នុងបញ្ជីនោះ ត្រូវបានបញ្ជាក់ថាបានបញ្ជូនពីកំពង់សោមទៅស-២១។ ចម្លើយសារភាពរបស់គាត់ត្រូវបានចាក់ផ្សាយនៅក្នុងវិទ្យុទីក្រុងភ្នំពេញ]។

[55] **D54/11** កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ដោយ កសចស, ត្រង់ A7-A9 ["គេយកទូកទាំងនោះមកដាក់នៅរាម។ ខ្ញុំធ្លាប់បានឃើញទូកជាច្រើនប្រភេទដែលគេចាប់បានយកមកទុកនៅរាម។... ទូកដែលខ្ញុំបានឃើញនៅរាម មានទូកប្រភេទ ១៥ ទៅ ៣៧សេស។ ចំពោះទូកដែលមានកម្លាំងលើសពីនេះ គេយកទៅប្រើក្នុងកងទ័ពជើងទឹក។... តាមខ្ញុំស្មានមានទូកចំនួនប្រហែលពី ៣០ ទៅ ៤០គ្រឿង"] និងនៅខាងក្រោម A31 ជា [យោបល់អ្នកស៊ើបអង្កេតទាក់ទងនឹងផែនទី D54/11.4 ដែលបានភ្ជាប់ជាមួយ]។ **D54/11.4** ផែនទីដែលបានភ្ជាប់ជាមួយនឹង D54/11 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ដោយ កសចស [ដោយបានបញ្ជាក់ពីទីកន្លែងទុកដាក់ទូកនេសាទដែលត្រូវបានចាប់]។ **D54/23** កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ដោយ កសចស, ត្រង់ A39។ **D8** កំណត់ហេតុស្តាប់ចម្លើយ សំ ប៊ុនឡេង ដោយ កសចស, ត្រង់ A1 ["ខ្ញុំមិនបានឃើញផ្ទាល់ភ្នែកនោះទេអំពីការចាប់ខ្លួនជនជាតិវៀតណាម និងថៃទាំងនោះ។ ខ្ញុំគ្រាន់តែបានឃើញទូកទាំងនោះ ត្រូវបានគេយកទៅទុកនៅផែរាម"]។

១៨- ស្រដៀងគ្នាទៅនឹងទីកន្លែងក្បែរបិទត្រាង និងកងកេងដែរ ពួកយោធា និងពួកជនស៊ីវិលត្រូវបានដាក់បង្ខំឱ្យធ្វើការនៅតាមទីកន្លែងពលកម្មនានានៅឃុំរាម ដែលបានប្រតិបត្តិការដោយកងពលលេខ ១៦៤[56]។ ដោយមកពីភូមិសាស្ត្រកន្លែងទាំងបីនោះនៅម្តុំជិតៗគ្នា ទំនងជាថាពេលខ្លះសាក្សីច្រឡំកន្លែងមួយទៅនឹងកន្លែងមួយផ្សេងទៀត[57]។ នៅម្តុំខែមេសា ឆ្នាំ ១៩៧៥ មានប្រជាជនជាច្រើននាក់ត្រូវបានបញ្ជូនដោយបង្ខំ ពិសេសមកពីទីរួមខេត្តកំពត ឱ្យទៅកាន់ភូមិនានាដូចជា៖ រាម ស្នាច់ដែង ឬព្រៃកចាក នៅក្នុងឃុំរាម[58]។ កងពលលេខ១៦៤ បានចោទប្រកាន់ "ពួកសមាសភាពមិនល្អ" ក៏ត្រូវបានបញ្ជូនឱ្យទៅធ្វើការនៅតាមបណ្តាភូមិទាំងនោះផងដែរ[59]។ ពួកទាំងអស់នោះ បន្ទាប់មកត្រូវឋិតនៅក្រោមវិធានសមូហកម្ម និងនៅក្រោមពលកម្មដោយបង្ខំយ៉ាងធ្ងន់ធ្ងរ[60] នៅតាមកង

---

[56] **D1.3.13.11** កំណត់ហេតុស្តាប់ចម្លើយ សៀង Sieng ដោយ កសព, ត្រង់ EN 00217565 ["នៅរាមមានសហករណ៍ដែលប្រពន្ធ-កូនរបស់កងពលលេខ១៦៤ រស់នៅជាមួយសេនាធិការកងទ័ព និងប្រជាជនធម្មតា។ មានប្រជាជនរាប់ពាន់នាក់នៅក្នុងសហករណ៍ទាំងនោះ"]។ **D2/6** កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ដោយ កសចស ត្រង់ A24, A28 ["អ្នកធ្វើការនៅទីនោះរួមមានទាំងប្រជាជន កងផលិត និងកងទ័ព។... ទាហានទាំងនោះ គឺគ្រប់កងទាំងអស់ ដែលមកពីកងវរសេនាធំ២២។ នៅពេលដែលពួកគេមានបញ្ហាអី ឬក៏មានទិន្នាការមិនល្អ គេនឹងត្រូវដកចេញពីវរសេនាធំ យកទៅដាក់នៅកងផលិតវិញ"]។ **D1.3.13.8** កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សារិន ដោយ កសព, ត្រង់ EN 00217561 ["ពួកគេធ្វើស្រែនៅស្នាច់ដែង ក្រោមការទទួលខុសត្រូវរបស់ តាង៉ែត Ta Nget ដែលជាមេបញ្ជាការ កងវរសេនាធំ"]។ **D2/10** កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ដោយ កសចស ត្រង់ A6 ["...កងអនុសេនាធំដែលសាក្សីធ្លាប់នៅ គឺកងអនុសេនាធំ២២ នៅស្នាច់ដែង"]។ **D1.3.13.11** កំណត់ហេតុស្តាប់ចម្លើយ សៀង Sieng ដោយ កសព, ត្រង់ EN 00217565 ["...ប្រធាន សហករណ៍រាយការណ៍ឱ្យទៅប្រធានអង្គភាពយោធាណាដែលនៅជិតខាងគេ គឺនៅរាម..."]។

[57] ជាឧទាហរណ៍, ធ្វើស្រែនៅខាងត្បូងព្រលានយន្តហោះកងកេង អាចត្រូវបានរៀបរាប់ថាជាកន្លែងពលកម្មដោយបង្ខំនៅកងកេង ឬនៅរាម។ បន្ថែមលើនេះ ដូចដែលបានពោលមកនៅខាងលើត្រង់កំណត់សម្គាល់ជើងទំព័រលេខ១០ បិទត្រាង នៅពេលនោះគេហៅថា ចំណោតរាម។

[58] **D11/373/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី (របាយការណ៍របស់ VSS) របស់ឈ្មោះ អ៊ុន ចន្ធា ត្រង់ EN 00991658 [ដោយពន្យល់អំពីរបៀបដែលប្រជាជនជាច្រើននាក់ និងក្រុមគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានជម្លៀសដោយបង្ខំនៅម្តុំថ្ងៃទី ១៧ មេសា ១៩៧៥ ពីទីរួមខេត្តកំពតទៅកាន់ភូមិរាម ឃុំរាម ស្រុកព្រៃនប់]។ **D11/385/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី (របាយការណ៍របស់ VSS) របស់ឈ្មោះ ព្រំ សាម៉ុន ត្រង់ EN 00991815។ **D11/387/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី (របាយការណ៍របស់ VSS) របស់ឈ្មោះ សំ វុទ្ធី Sam Vuthy ត្រង់ EN 0091850 ["ឆ្នាំ១៩៧៥ សមាជិកគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានជម្លៀសដោយបង្ខំទៅកាន់ភូមិស្នាច់ដែង ឃុំរាម ស្រុក ព្រៃនប់ ខេត្តព្រះសីហនុ"]។

[59] ជាឧទាហរណ៍, **D54/35** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ដោយ កសចស, ត្រង់ A14 ["កងចល័តនោះ គឺមានអតីតៈយោធាកងពល១៦៤ ណា ដែលចាត់ទុកថា សមាសភាពមិនល្អ កងចល័តនោះ គឺឋិតនៅក្រោមការគ្រប់គ្រងរបស់កងពល១៦៤ ដដែលហើយគេបញ្ជូនទៅឱ្យធ្វើការនៅកន្លែងមួយហៅថា ភូមិព្រៃកចាក ឋិតនៅប្រហែលពីរគីឡូម៉ែត្រខាងកើតផែរាម"]។

[60] **D11/373/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី (របាយការណ៍របស់ VSS) របស់ឈ្មោះ អ៊ុន ចន្ធា ត្រង់ EN 00991658 ["នៅពេលនោះ ទ្រព្យសម្បត្តិរបស់ប្រជាជនទាំងអស់ត្រូវបានរឹបអូសដើម្បីប្រើប្រាស់សម្រាប់ជាគោលបំណងសាធារណៈ... គេតម្រូវឱ្យពួកប្រជាជនហូបជាសមូហភាព"]។ **D11/385/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី (របាយការណ៍របស់ VSS) របស់ឈ្មោះ ព្រំ សាម៉ុន, ត្រង់ EN 00991815 ["... ទ្រព្យសម្បត្តិទាំងអស់របស់គាត់ត្រូវបានរឹបអូសយកទៅប្រើប្រាស់រួម... ខ្មែរក្រហមបានបញ្ជាឱ្យប្រជាជនហូបរួម និងធ្វើការរួម"]។ **D11/387/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី

ចល័តនៅរាម ឬនៅតាមសហករណ៍នានា ដែលមានប្រជាជនរាប់ពាន់នាក់ រួមមាន ស្ត្រី កុមារ ចាស់ជរា និង ជនពិការផង ឲ្យធ្វើការដោយមិនគិតពីលក្ខខណ្ឌអ្វីឡើយ[61]។ ប្រភេទផ្សេងៗនៃពលកម្មដោយបង្ខំ នៅតាមទីកន្លែងទាំងនោះ រួមមាន ធាក់រហាត់ទឹកបញ្ចូលស្រែ ការដាំដំណាំ ការរែកដី និងការសាងសង់ទំនប់[62]។ មនុស្សជាច្រើននាក់ត្រូវបានគេសម្លាប់ចោល[63]។

(របាយការណ៍របស់ VSS) របស់ឈ្មោះ សំ វុទ្ធី Sam Vuthy ត្រង់ EN 0091850 ["របបហូបចុក គឺអង្ករពីរកំប៉ុងក្នុងមួយថ្ងៃសម្រាប់មួយគ្រួសារទាំងមូល។ សមមិត្ត លន់ Lonn បានបង្ខំពួកបុរសទាំងអស់ឲ្យរែកដីធ្វើទំនប់ទាំងថ្ងៃទាំងយប់។ ពេលយប់ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបង្ខំឲ្យធ្វើការរហូតដល់ម៉ោង១០"]។ **D1.3.13.8** កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សារិន ដោយ កសព, ត្រង់ EN 00217561 ["នៅរាម មានកម្លាំង៦០០នាក់ ដែលគេបានផ្តល់អាហារឲ្យតែពេលថ្ងៃត្រង់ និងពេលល្ងាច។ នេះមានតែបបរពីរវែក - ស្មើនឹងមួយចានក្នុងមួយថ្ងៃ។ ដើម្បីរស់ អ្នកខ្លះស្វែងរកសត្វ និងដើមឈើ ដើម្បីស៊ីជាអាហារ។ ពួកប្រជាជនចាំបាច់ត្រូវតែធ្វើតាមច្បាប់អង្គការ - ច្បាប់សម្រាប់ធ្វើការងារ សម្រាប់ដេក សម្រាប់ស៊ី - ទាំងអស់នេះថិតនៅលើច្បាប់របស់អង្គការ"]។

[61] **D11/373/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី (របាយការណ៍របស់ VSS) របស់ឈ្មោះ អ៊ុន ចន្ថា ត្រង់ EN 00991658 ["ប្រជាជន (ក្មេង ចាស់ និង ជនពិការ) ត្រូវបានបង្ខំឲ្យធ្វើការ ដោយមិនគិតថាជាជនពិការ ឬជាចាស់ ឬជាក្មេងទេ"]។ **D1.3.13.8** កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សារិន ដោយ កសព, ត្រង់ EN 00217561 ["នៅរាម មានកម្លាំង៦០០នាក់… មានសហករណ៍ពីរនៅរាម សម្រាប់ប្រពន្ធ និងកូនៗរបស់ពួកយុទ្ធជន និងអ្នកធ្វើការ…"]។ **D1.3.13.11** កំណត់ហេតុស្តាប់ចម្លើយ សៀង Sieng ដោយ កសព, ត្រង់ EN 00217565 ["នៅរាមមានសហករណ៍ដែលប្រពន្ធ-កូន របស់កងពលលេខ១៦៤ រស់នៅជាមួយសេនាធិការកងទ័ព និងប្រជាជនធម្មតា។ មានប្រជាជនរាប់ពាន់នាក់នៅក្នុងសហករណ៍ទាំងនោះ"]។ **D2/6** កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ដោយ កសចស ត្រង់ A24, A28 ["អ្នកធ្វើការនៅទីនោះរួមមានទាំងប្រជាជន កងផលិត និង កងទ័ព។… ទាហានទាំងនោះ គឺគ្រប់កងទាំងអស់ដែលមកពីកងវរសេនាធំ២២។ នៅពេលដែលពួកគេមានបញ្ហាអី ឬក៏មាននិន្នាការមិនល្អ គេនឹងត្រូវដកចេញពីវរសេនាធំ យកទៅដាក់នៅកងផលិតវិញ"]។

[62] **D11/385/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី (របាយការណ៍ របស់ VSS) របស់ឈ្មោះ ព្រំ សាម៉ុន, ត្រង់ EN 00991815 ["បុរសចាស់ៗត្រូវបានចាត់តាំងឲ្យវេញខ្សែ រីឯស្ត្រីចាស់ៗត្រូវបានចាត់តាំងឲ្យមើលទារក។ អ្នកដទៃទៀតត្រូវបានបញ្ជាឲ្យទៅធ្វើស្រែ រែកដី និង សង់ទំនប់។ ផ្ទុយទៅវិញ ពួកកុមារៗចាប់ពីអាយុ១០ឆ្នាំទៅ ត្រូវបានចាត់តាំងឲ្យទៅកងកុមារ ដោយមិនគិតថាពួកគេឈឺ ឬ [ពិការ] ទេ"]។ **D11/387/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី (របាយការណ៍របស់ VSS) របស់ឈ្មោះ សំ វុទ្ធី Sam Vuthy ត្រង់ EN 0091850 ["សមមិត្ត ប៉ែន Pen ប្រធានភូមិ បានចាត់តាំងឪពុក-ម្តាយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឲ្យធ្វើស្រែ និងដាំដំណាំ"]។ **D1.3.13.8** កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សារិន ដោយ កសព, ត្រង់ EN 00217561 ["ពួកគេធ្វើស្រែនៅ ស្នាច់ដែង ក្រោមការទទួលខុសត្រូវរបស់ តាង៉ែត Ta Nget ដែលជាមេបញ្ជាការកងវរសេនាធំ"]។ **D2/7** កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សារិន ដោយ កសចស, ត្រង់ A3 ["…គេមិនដកខ្ញុំទៅសមរភូមិក្រោយទេ គេបានទុកឲ្យខ្ញុំនៅបម្រើការក្នុងជួរកងទ័ព។ ចំណែកបុគ្គលិកមួយចំនួនផ្សេងទៀតត្រូវបានបញ្ជូនទៅការដ្ឋាននៅតំបន់ស្នាច់ដែង និងវាលរេញ"]។ **D2/10** កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ដោយ កសចស ត្រង់ A6 ["…កងអនុសេនាធំដែលសាក្សីធ្លាប់នៅ គឺកងអនុសេនាធំ២២ នៅស្នាច់ដែង"]។ **D11/387/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី (របាយការណ៍របស់ VSS) របស់ឈ្មោះ សំ វុទ្ធី Sam Vuthy ត្រង់ EN 0091850 ["ឆ្នាំ១៩៧៦ សមមិត្ត លន់ Lonn និង សមមិត្ត គឿន Keoun បានចាត់តាំងដើមបណ្តឹងរដ្ឋប្បវេណីឲ្យធ្វើទំនប់ពត់ទ្រើង Pott Threoung Dam នៅភូមិស្នាច់ដើង ឃុំរាម"]។ **D2/6** កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ដោយ កសចស ត្រង់ A27 ["ទំនប់[ស្នាច់ដែង]នេះចាប់ផ្តើមធ្វើនៅឆ្នាំ១៩៧៧។ ទំនប់ត្រូវបានធ្វើចប់ប្រហែលជាបី-បួនខែ នៅក្នុងឆ្នាំដដែល"]។

[63] សូមអាន,ជាឧទាហរណ៍, **D11/378/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី (របាយការណ៍របស់ VSS) របស់ឈ្មោះ ឌិន កាន Din Kan ត្រង់ EN 00991593 ["គាត់ត្រូវបានប្រាប់ថា… ឪពុក-ម្តាយរបស់គាត់ ប្អូនប្រុសរបស់គាត់ (…) និងប្អូនស្រី

១៩- សពអ សូមបំភ្លឺថា ចំការធូរ៉េន ដូចបានលើកឡើងខាងលើក្នុងកថាខណ្ឌ៦ (ទាក់ទងនឹងបិតត្រាំង) និងកថាខណ្ឌ៨ (កងកេង) ដែលស្ថិតនៅក្នុងឃុំរាម ហើយដែលគេយកធ្វើជាទីតាំងសម្លាប់មនុស្ស ផងដែរសម្រាប់កម្មករធ្វើការដោយបង្ខំនៅរាម ក្រោមអំណាចរបស់កងពលធំ១៦៤ (មនុស្សដែលបានប្រព្រឹត្តកំហុសអ្វីមួយ អ្នកដែលគេចោទថាជាជនក្បត់ ជនពិការ និងអ្នកដែលធ្វើការងារមិនបានល្អ[64]) និងសម្រាប់មនុស្សដែលបានត្រូវចាប់ខ្លួនដោយកងពលធំ១៦៤ ពីសមុទ្រ[65]។ ការសម្លាប់

---

របស់គាត់ (...) ត្រូវបានសម្លាប់នៅក្នុងអំឡុងពេលនៃរបបនោះដោយ (...) នៅភូមិរាម ស្រុកព្រៃនប់..."]។ **D11/367/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី (របាយការណ៍របស់ VSS) របស់ឈ្មោះ សាន សារ៉េត San Saret ត្រង់ EN 00991577 ["ឆ្នាំ១៩៧៨... ឪពុក និងបង-ប្អូនប្រាំមួយនាក់របស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានយកទៅសម្លាប់នៅនៅភូមិរាម ឃុំរាម ស្រុកព្រៃនប់..."]។ និង **D11/373/1** របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី (របាយការណ៍របស់ VSS) របស់ឈ្មោះ អ៊ុន ចន្ទា ត្រង់ EN 00991658-9 ["ពួកអ្នកដែលបំពេញការងាររបស់ខ្លួនមិនបានល្អ និងពួកជនពិការត្រូវបានសម្លាប់ចោល នៅលើពាក្យស្លោកមួយ *"ទុកមិនចំណេញ ដកចេញមិនខាត"*។ ពេលខ្លះ ពួកខ្មែរក្រហមបានសម្លាប់មនុស្សដោយសារតែជាជនក្បត់"]។

[64] **D2/6** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ ញូង ជ្រោង, ត្រង់ A40 ["... ខ្ញុំបានឮគេនិយាយថា ក្រោយពេលគេចាប់បានមនុស្សដែលមានកំហុសរួចហើយ គេក៏បញ្ជូនពួកគេទៅកន្លែងនោះ ដើម្បីយកទៅធ្វើជីនៅចំការទុរេន"]។ **D11/373/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (របាយការណ៍ VSS) របស់ អ៊ុន ចន្ទា, ត្រង់ ERN ជាភាសាអង់គ្លេស 00991658 ["អ្នកធ្វើការមិនបានល្អ និងជនពិការ ត្រូវគេសម្លាប់ចោលដោយផ្អែកលើពាក្យស្លោករបស់ពួកគេថា *"ទុកមិនចំណេញ ដកចេញមិនខាត"*។ ជួនកាល ខ្មែរក្រហមសម្លាប់មនុស្ស ដោយសារពួកគេជាមនុស្សក្បត់"]។ EN 00991659 ["អ្នកដាក់ពាក្យសុំបាននិយាយថា ក្មេងៗ និងមនុស្សចាស់ត្រូវបានគេចងដៃទៅក្រោយ រួចយកទៅសម្លាប់នៅចំការធុរ៉េន នៅភូមិរាម (...)។ ជាការបន្ថែម បងប្រុស បងស្រី មីង និងអ៊ុំប្រុសរបស់គាត់ ក៏ត្រូវបានគេយកទៅសម្លាប់នៅចំការធូរេន ដែរ"]។ **D11/370/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (របាយការណ៍ VSS) របស់ ផាន រិន, ត្រង់ ERN ជាភាសាអង់គ្លេស 00991609-10 ["អ្នកធ្វើការមិនបានល្អ ត្រូវបាត់ខ្លួន។ អ្នកដាក់ពាក្យសុំធ្លាប់បានឃើញមនុស្សដែលគេយកទៅសម្លាប់នៅចំការទុរេន......"]។ **D11/385/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី(របាយការណ៍ VSS) របស់ ព្រំ សាម៉ុន, ត្រង់ ERN ជាភាសាអង់គ្លេស 00991816 "នាងបានឃើញមនុស្សជាច្រើន រួមទាំងបងប្អូនរបស់នាងផង ត្រូវបានគេចង និងនាំយកទៅចំការទុរេន នៅភូមិរាម"។ **D2/17** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ អ៊ិន សារឿន, ត្រង់ A7, A11, A13 ["ខ្ញុំបានឮថា គេនាំយកទៅសម្លាប់នៅចំការទុរេន... ខ្ញុំបានឃើញក្នុងឆ្នាំ១៩៧៦។ នៅពេលហ្នឹង គេចាប់ផ្តើមសម្លាប់មនុស្សហើយ រួមទាំងខ្មែរផង។ ប្អូនប្រុសខ្ញុំម្នាក់ ក៏គេសម្លាប់ចោលដែរ"]។ **D11/374/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (របាយការណ៍ VSS) របស់ នាក់ ស៊ីថា, ត្រង់ ERN ជាភាសាអង់គ្លេស 00991675 ["នៅក្នុងរបបនេះ អ្នកដាក់ពាក្យសុំបានបាត់បង់បងប្អូនដូចខាងក្រោម ដែលត្រូវបានពួកកម្មាភិបាលខ្មែរក្រហម នាំយកទៅសម្លាប់ចោលនៅចំការទុរេន នៅភូមិរាម ឃុំរាម..."]។

[65] **D54/18** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ នូ សារឿន, ត្រង់ A33-A34, A41, និង A43-A44 ["ខ្ញុំបានឃើញយោធាខ្មែរក្រហម បញ្ជូនអ្នកនេសាទដែលចាប់បានទៅចំការទុរេន។ អ្នកនេសាទទាំងនោះ ត្រូវបានប្រគល់ទៅឱ្យអង្គភាពខ្មែរក្រហមមួយផ្សេងទៀត ដើម្បីយកទៅសម្លាប់នៅទីនោះ... ជាធម្មតា គ្មាននរណាម្នាក់នៅរស់ឡើយ បន្ទាប់ពីបានបញ្ជូនទៅទីនោះ"]។ **D2/17** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ អ៊ិន សារឿន, ត្រង់ A10-A11, A15-A24, A27-A28, A43 ["ខ្ញុំឃើញទាហាន ប៉ុល ពត នាំយកជនជាតិថៃទៅសម្លាប់ចោលនៅទីនោះ... ខ្ញុំឃើញទាហាន ប៉ុល ពត ចងពួកគេបណ្តើរកាត់ទឹកទៅកាន់ឆ្នេរ។ ខ្ញុំឮគេថា ពួកគេត្រូវគេនាំយកទៅសម្លាប់នៅចំការទុរេន...។ ពីរបីថ្ងៃក្រោយមកឪពុកខ្ញុំបានប្រាប់ខ្ញុំថា ពួកគេបានចាប់មនុស្សយកទៅសម្លាប់នៅចំការទុរេន"]។ **D2/6**

ផ្សេងទៀត ត្រូវបានធ្វើឡើងដោយកងពល១៦៤ នៅចំការក្បែរនោះឈ្មោះថា ចំការដូង (ឬចំការដូងចេងហេង)ដែលមានទីតាំងនៅសមុទ្ររាម និងចំការក្រូច[66]។ ការសម្លាប់ទាំងនេះហាក់ដូចជាត្រូវបានធ្វើឡើងដោយកងវរសេនាធំ៦២[67]។

## ឧក្រិដ្ឋកម្មបន្ថែម

*កងពលធំ១៦៤ - អាពាហ៍ពិពាហ៍ដោយបង្ខំ*

២០- ជាផ្នែកមួយនៃគោលនយោបាយនៃការបង្កើតគ្រួសារបដិវត្ត និងកំណើនប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យឲ្យបានឆាប់រហ័សនៅទូទាំងប្រទេស[68] ភ័ស្តុតាងនានាដែលទទួលបានតាំងពីពេលដាក់

---

កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ ញូង ជ្រោង, ត្រង់ A42-A44 [“ស: ចំពោះអ្នកនេសាទថៃ និងវៀតណាម បន្ទាប់ពីពួកគេត្រូវបានចាប់ខ្លួន តើគេយកពួកគេទៅសម្លាប់នៅទីកន្លែងនោះដែរឬទេ? A42: បាទ, គឺគេនាំយកពួកគេទៅសម្លាប់នៅទីកន្លែងនោះដែរ... ក្រុមខាងកងវរៈសេនាធំ៦២ ជាអ្នកនាំមនុស្សពីរាម យកទៅសម្លាប់នៅចំការទុរេន...”]។ **D54/26** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ ប៉ាក សុខ, ត្រង់ A12-A13 [“បើតាមខ្ញុំដឹង មានវៀតណាមរាប់រយនាក់ត្រូវបានគេនាំយកទៅសម្លាប់នៅទីនោះ... ភារកិច្ចរបស់សមាជិកយោធាទាំងនោះ គឺចាំទទួលវៀតណាមដែលចាប់បាន ដើម្បីយកទៅសម្លាប់នៅចំការទុរេន និងចំការដូង”]។ **D2/16** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ ទូច សឿលី, ត្រង់ A32-A33 [“យើងគ្រាន់តែបានឮគេនិយាយតៗគ្នាតែប៉ុណ្ណោះ។ ខ្ញុំបានឮថា ថៃ និង វៀតណាម ដែលចាប់បាន ត្រូវបាននាំយកទៅសម្លាប់នៅកន្លែងមួយដែលគេហៅថា ចំការទុរេន...”]។

[66] **D54/26** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ ប៉ាក សុខ, ត្រង់ A13 [“...ចំការទុរេន ចំការដូង និងចំការក្រូច គឺនៅជិតគ្នា”]។ **D54/26.1** ប៉ាក សុខ បានចារលើផែនទីរដ្ឋបាលព្រះសីហនុ ២០០៨-២០១០ [ប៉ាក សុខ បានគូសបង្ហាញទីតាំងចំការទុរេន ចំការដូង និងចំការក្រូច ដែលស្ថិតនៅភាគខាងត្បូងបិទត្រាង និងភាគខាងលិចផែសមុទ្ររាម នៅជិតគ្នា និងខាងលើវាលទំនាប និងទីជម្រាលមួយ]។ **D2/17** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ អ៊ិន សារឿន, ត្រង់ A9 [“ចំការដូង នៅពេលនោះ ស្ថិតនៅមិនឆ្ងាយប៉ុន្មានពីចំការទុរេនទេ”]។ **D54/17** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ សយ ប៊ិន, ERN ជាភាសាអង់គ្លេស ត្រង់ 00977272 [“ពេទ្យកងពលធំ១៦៤ នៅរាម នៅមាត់សមុទ្រចំការដូងចេងហេង នៅភាគនិរតីនៃព្រលានយន្តហោះកងកេង”]។ **D54/8** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ ឌុល សុង, ត្រង់ A24 [“ខ្ញុំស្គាល់ចំការដូង គឺនៅជាប់នឹងឆ្នេរសមុទ្ររាម ពីព្រោះមានមន្ទីរពេទ្យមួយនៅទីនោះ”]។

[67] **D2/6** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ ញូង ជ្រោង, ត្រង់ A43- A44 [“... ដូច្នេះ ក្រុមខាងកងវរៈសេនាធំ៦២ ជាអ្នកដែលនាំមនុស្សពីរាម យកទៅសម្លាប់ចោលនៅចំការធុរ៉េន”]។ **D54/26** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ ប៉ាក សុខ, ត្រង់ A12 [“... វៀតណាមរាប់រយនាក់ត្រូវបានសម្លាប់នៅទីនោះ”]។ A13 [“...កងវរៈសេនាតូចមួយដែលមានយោធាប្រហែល១៥០នាក់ នៃកងវរៈសេនាធំ៦២ ត្រូវបានដាក់ឲ្យឈរជើងនៅទីនោះ។ ភារកិច្ចរបស់សមាជិកយោធាទាំងនោះ គឺចាំទទួលវៀតណាមដែលចាប់បាន និងយកមកសម្លាប់ចោលនៅចំការទុរេន និងចំការដូង...”]។

[68] **CF2 D115/2.2 (E3/1337)**, កំណត់ត្រាពីក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ, អង្គការសហប្រជាជាតិ ECOSOC, ២២ មេសា ១៩៧៨ ត្រង់ ERN ជាភាសាខ្មែរ 00701216, ERN ជាភាសាអង់គ្លេស 00235727, ERN ជាភាសាបារាំង 00235736 [“បីឆ្នាំបន្ទាប់ពីការរំដោះកម្ពុជាបានទាំងស្រុង គោលនយោបាយដើម្បីបង្កើនប្រជាជនត្រូវបានគេធ្វើឡើង

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ បង្ហាញថាមន្ត្រីកងពលធំ១៦៤ បានប្រព្រឹត្តអាពាហ៍ដោយបង្ខំនៅតំបន់កំពង់សោម ដែលបានដាក់ឱ្យស្ថិតក្រោមការត្រួតត្រា ឬសិទ្ធិអំណាចរបស់ មាស មុត។

២១- អាពាហ៍ពិពាហ៍ដោយបង្ខំនៅក្រោមអំណាចរបស់មេដឹកនាំយោធានៃកងពលធំ១៦៤នេះ ផ្តោតជាពិសេសទៅលើស្ត្រីនៅលីវ និងបុរសនៅលីវមានអាយុចន្លោះ២០ឆ្នាំឡើង[69]។ មានជនរងគ្រោះខ្លះ

---

ហើយបានទទួលលទ្ធផលជោគជ័យជាលើកដំបូងរបស់ខ្លួន" **D4.1.874,** យុវជន យុវនារី បដិវត្ត, វិច្ឆិកា ១៩៧៥, អត្ថបទទី២ មានចំណងជើងថា "ដើម្បីលុបបំបាត់កម្មសិទ្ធិសួនតួជាដាច់ខាត និងពង្រឹង និងពង្រីកកម្មសិទ្ធិសមូហភាពឱ្យបានខ្លាំងក្លា" ត្រង់ ERN ជាភាសាខ្មែរ 00063614-15, ERN ជាភាសាអង់គ្លេស 00522460, ERN ជាភាសាបារាំង 00525856-57 ["តាមឋានានុក្រមបដិវត្តយើង យុវជន យុវនារី និងកម្មាភិបាលបដិវត្ត បានលះបង់ចោលកម្មសិទ្ធិសួនតួ ដូចជាផ្ទះ ស្រែចំការ សួនច្បារ គ្រួសារ សាច់ញាតិបងប្អូន កូនចៅ និងទ្រព្យសម្បត្តិដទៃទៀតដើម្បីបំរើបក្ស បដិវត្ត និងប្រជាជន"]។ **CF2 D267/3.36 (E3/775),** ការបោះពុម្ពផ្សាយរបស់ បកក មានចំណងជើងថា "លោកទស្សនៈ បដិវត្ត និងមិនបដិវត្ត ចំពោះបញ្ហាកសាងគ្រួសារ", *ដែលជាការបោះពុម្ពឡើងវិញយ៉ាងត្រឹមត្រូវនៃទស្សនាវដ្តី យុវជនយុវនារីបដិវត្តន៍ ចេញផ្សាយថ្ងៃទី២ មិថុនា ១៩៧៥,* ត្រង់ ERN ជាភាសាខ្មែរ 00407100, ERN ជាភាសាអង់គ្លេស 00417942-43, ERN ជាភាសាបារាំង 00593929 [*"ដូច្នេះ* ការកសាងគ្រួសារបដិវត្តរបស់យើង គេមិនត្រឹមតែសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន ឬសុភមង្គលរបស់យើង ឬក៏ដើម្បីគ្រាន់តែឱ្យមានកូនចៅដើម្បីបន្តគ្រួសារយើងប៉ុណ្ណោះទេ។ សំខាន់ គឺថាដើម្បីឱ្យបដិវត្តសម្រេចបានបេសកកម្មដ៏ខ្ពង់ខ្ពស់របស់ខ្លួនដើម្បីរំដោះជាតិ..."] ត្រង់ ERN ជាភាសាខ្មែរ 00407100-01, ERN ជាភាសាអង់គ្លេស 00417943, ERN ជាភាសាបារាំង 00593930 ["១. (...) ពេលកំពុងរៀបការ សំខាន់បំផុតត្រូវលើកសំណើដោយស្មោះត្រង់ជូនអង្គការ ជូនសមូហភាព ដើម្បីឱ្យគេជួយដោះស្រាយបញ្ហាទាំងនោះ។ ២. វិន័យអង្គការត្រូវគោរពជាដាច់ខាត។ ចំពោះបញ្ហានៃការកសាងគ្រួសារវិញ មិនថាលទ្ធផលសម្រេចរបស់អង្គការ ឬសមូហភាពយ៉ាងណាទេ គឺត្រូវគោរពជាដាច់ខាត"]។ **CF2 D252.13 (E3/1113),** សារទូរលេខ ខ្ទង់៦១ ពីកន ជូនបងជាទីគោរពស្នេហា, បានទទួលនៅថ្ងៃទី១៥ មីនា ១៩៧៨, ត្រង់ ERN ជាភាសាខ្មែរ 00020965-66, ERN ជាភាសាអង់គ្លេស 00434864, ERN ជាភាសាបារាំង 00623009 [*"កន ឆ្លើយ: (...) សមាជិកកងចល័តត្រូវបានអនុញ្ញាតឱ្យរៀបការ ប្រសិនបើគេបានស្នើឡើង។ គណៈបញ្ជាការកងចល័តរបស់សហករណ៍ជាអ្នកសម្រេចឱ្យរៀបការ"]*។ **D54/74.1.20,** សៀវភៅរបស់លោក Philip SHORT មានចំណងជើងថា "ប៉ុល ពតៈ ប្រវត្តិសាស្ត្រនៃសុបិនអាក្រក់មួយ" Pol Pot: The History of a Nightmare", ត្រង់ ERN ជាភាសាអង់គ្លេស 00396533-34, ERN ជាភាសាបារាំង 00639883 [""គ្រួសារបន្តនៅមាន ប៉ុន្តែ (...) គោលបំណងជាចំបងរបស់វា គឺប្រែក្លាយ "កុមារឱ្យទៅជាអ្នកបំរើបក្ស'។ ចំណងទាក់ទងរបស់បុគ្គលនៃសមាជិកគ្រួសារត្រូវបានដាក់ពង្រាយនៅក្នុងសហគមធំ... 'ការជ្រើសរើសគូស្រករដោយសេរី'ត្រូវបានផ្តន្ទាទោសយ៉ាងដាក់ស្តែង"]។ **D4.1.1056** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ ដួន ធី, ត្រង់ A4 ["(ប៉ុល ពត នៅក្នុងសន្និសីទមួយ) បានបន្ថែមថា *"ក្នុងរយៈពេល១០ ទៅ ២០ ឆ្នាំទៀត យើងត្រូវតែបង្កើនចំនួនប្រជាជនឱ្យបានចន្លោះពី ២០ ទៅ ៣០លាននាក់ដើម្បីឱ្យមានកម្លាំងគ្រប់គ្រាន់សម្រាប់ការពារប្រទេសយើង"*។ ក្នុងន័យនេះ ប៉ុល ពត បានថ្លែងថា គាត់ត្រូវការឱ្យមានការរៀបចំនូវការរៀបការដើម្បីបង្កើនចំនួនប្រជាជន ដោយដាក់ការណែនាំឱ្យថ្នាក់ក្រោមរៀបចំការរៀបការប្រជាជន"]។

[69] **D59/1/1.7a** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ា ឈឿន និង ស៊ួន វ៉ាត (Ma Chhoeun and Suon Vat) (DC-Cam), ត្រង់ ERN ជាភាសាអង់គ្លេស 00969949-50 ["តាមខ្ញុំឃើញ នារីៗដែលមានអាយុពី២០ ទៅ២១ ឬ ២២ឆ្នាំ បុរសមានអាយុចន្លោះពី២០ ទៅ៣០ឆ្នាំ"]។ **CF2 D232/71** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ សេង អុល, ត្រង់ A27 ["ខ្ញុំបានជ្រើសរើសនារីដែលមានលក្ខណៈពេញវ័យ ដែលមានអាយុចាប់ពី២០ឆ្នាំឡើង"]។

ជាស្ត្រីមេម៉ាយដែលមានកូន[70]។ ជួនកាល ស្ត្រីដែលត្រូវគេបង្ខំឲ្យរៀបការនោះត្រូវបានស្នើឡើងជាពិសេសដោយកងពលធំ១៦៤ ព្រមទាំងត្រូវបានបញ្ជូនពីភូមិភាគ ឬតំបន់ផ្សេងមកកាន់កំពង់សោម៖ ក្នុងឆ្នាំ១៩៧៧-១៩៧៨ ថ្នាក់ដឹកនាំកងពលធំ១៦៤ បានបញ្ជាឲ្យមេឃុំត្រាំកក់"ស្នើ"ឲ្យស្ត្រីនៅមូលដ្ឋានរៀបការ នៅកំពង់សោម។ មេឃុំ និងស្ត្រីដែលត្រូវបានជ្រើសរើសក្នុងឃុំនិមួយៗ មិនបានដឹងថា ពួកគេនឹងត្រូវគេបង្ខំឲ្យរៀបការជាមួយទាហានពិការឡើយ[71]។

២២- មាស មុត បានរៀបចំឲ្យមានការរៀបការជាក្រុមឲ្យកម្មាភិបាល និងយុវជន/យុវនារី[72]។ សូម្បីតែពួកកម្មាភិបាលថ្នាក់ខ្ពស់នៃកងពលធំ១៦៤ ក៏ត្រូវបានគេបង្ខំឲ្យរៀបការដែរ ដែលជួនកាលតាមការផ្តួចផ្តើមរបស់ មាស មុត៖ ឧទាហរណ៍ គាត់បានរៀបចំការរៀបអាពាហ៍ពិពាហ៍នៅផ្ទះរបស់គាត់ឲ្យបងប្អូនស្រីគាត់ម្នាក់ ជាមួយនឹងអនុប្រធានកងវរសេនាតូច១៤២ (កងវរសេនាធំ១៤០ កងពលធំ១៦៤) មានឈ្មោះ លៀត ឡូន *ហៅ* ណាំ ឡូន ដែលគាត់ត្រូវបានគេប្រាប់ថាឲ្យមកប្រជុំជាមួយ មាស មុត ដោយមិនដឹងថា គាត់ត្រូវគេបង្ខំឲ្យរៀបការទេ[73]។

---

[70] **D2/7** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ ប៉ែន សារិន, ត្រង់ជាភាសាអង់គ្លេស 00607254 [(នៅ កំពង់សោម) "សាក្សីបានរៀបការពីរដង... ប្រពន្ធរបស់គាត់... ពួកគេបានរៀបការនៅខែមិថុនា ឆ្នាំ១៩៧៧ (ពួកគេបង្ខំ[ឲ្យយើង]រៀបការ)។ 'ខ្ញុំមានកូនបួននាក់ជាមួយប្រពន្ធមុន...។ ពេលគេបង្ខំខ្ញុំឲ្យរៀបការជាមួយប្រពន្ធទីពីរក្នុងរបបខ្មែរក្រហម គាត់មានកូន៧នាក់រួចហើយ...។ អញ្ចឹង ខ្ញុំ និងប្រពន្ធទីពីររបស់ខ្ញុំ មានកូនទាំងអស់១០នាក់"]។

[71] **CF2 D232/71** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ សេង អុល, ត្រង់ A20, A22, A27 [A20 "ក្នុងឆ្នាំ ១៩៧៧ ឬ ១៩៧៨, កងទ័ពបានមកស្នើពីអង្គភាពខ្ញុំនៅកំពង់សោម ដើម្បីរៀបការ។ លិខិតស្នើសុំ ត្រូវបានបញ្ជូនពីខាងកងទ័ព មកឃុំខ្ញុំ ហើយគណៈឃុំបានប្រាប់ខ្ញុំឲ្យជ្រើសយកស្រីៗទៅកំពង់សោម ដោយនិយាយថា កងទ័ពបានស្នើសុំពួកគេ។ នៅពេលហ្នឹង ទាំងខ្ញុំ ទាំងស្រីៗដែលបានជ្រើសរើស គ្មាននរណាម្នាក់ដឹងថាពួកគេនឹងត្រូវនាំយកទៅរៀបការជាមួយទាហានពិការឡើយ។ បើតាមខ្ញុំយល់ ទាហានទាំងនោះមិនមែនជាទាហានដែលពិការធ្ងន់ធ្ងរទេ ពួកគេគ្រាន់តែពិការបន្តិចបន្តួចប៉ុណ្ណោះ។ ខ្ញុំបានជ្រើសយកស្ត្រីពីបីទៅប្រាំនាក់ ពីក្នុងអង្គភាពខ្ញុំ។ ការជ្រើសរើសមិនមែនធ្វើតែនៅក្នុងអង្គភាពរបស់ខ្ញុំនោះទេ តាមបណ្តាឃុំខុសៗគ្នាជាច្រើនទៀតក៏ធ្វើដូចគ្នានេះដែរ"។ A22: "ខ្ញុំមិនថាស្ត្រីទាំងនោះស្ម័គ្រចិត្ត ឬអត់នោះទេ ឬប៉ុន្តែគ្មានស្ត្រីណាម្នាក់ប្រកែកឡើយ"]។

[72] **D59/1/1.7a** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ា ឈឿន និង ស៊ួន វ៉ាត (Ma Chhoeun and Suon Vat) (DC-Cam), ត្រង់ ERN ជាភាសាអង់គ្លេស 00969949-50 ["មានប្តីប្រពន្ធជាច្រើន។ គេធ្វើនៅកំពង់សោម។ ៣០នាក់។ គេប្រាប់យើងឲ្យទៅប្រមូលមនុស្សមករៀបការ។ វាចម្រុះគ្នា [កម្មាភិបាលនិងយុទ្ធជនយុទ្ធនារី]... *តាម មុត* [ជាអ្នកណែនាំឲ្យរៀបការ]។ គាត់ជាប់រវល់ ដូច្នេះគាត់មិនបានចូលរួមទេ"]។

[73] **D54/29** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ លៀត ឡូន *ហៅ* ណាំ ឡូន, ត្រង់ A3 (EN 00976573) ["ប្រហែល១ខែ ឬពីរខែ[ក្រោយ] អ្នកធ្វើការខាងវិទ្យុបានទាក់ទងខ្ញុំ ដោយប្រាប់ខ្ញុំថា មាស មុត ចង់ជួបខ្ញុំនៅផ្ទះគាត់។ ពេលខ្ញុំមកដល់កំពង់ផែ ខ្ញុំឃើញម៉ូតូមួយកំពុងរង់ចាំខ្ញុំរួចជាស្រេច។ ពេលខ្ញុំមកដល់ផ្ទះគាត់នៅជិតផ្សារកំពង់សោម ខ្ញុំបានឃើញកម្មាភិបាលជាន់ខ្ពស់ខ្លះបានមកប្រមូលផ្តុំគ្នានៅទីនោះរួចជាស្រេចហើយ។ ដំបូង ខ្ញុំអត់ដឹងថាមានអ្វីកើតឡើងនៅទីនោះទេ។ ភ្លាមនោះ *តា* ញ៉ាន [*Ta* Nhan] បានហៅកូនក្រមុំឲ្យចេញមកក្រៅ ហើយគាត់ក៏ប្រកាសអំពីការរៀបការតែម្តង...។ ខ្ញុំគិតថា *តា* មុត គឺជាអ្នកផ្តួចផ្តើមគំនិតនៃការរៀបការរបស់ខ្ញុំ។ ខ្ញុំមិនបានដឹងពីមូលហេតុពិត

២៣- ដោយសារតែជាញឹកញាប់ ជនរងគ្រោះជាបុរស និងជនរងគ្រោះជាស្ត្រី ត្រូវបានគេបង្ខំឲ្យរៀបការជាមួយមនុស្សចម្លែក ឬមនុស្សដែលគេមិនស្រឡាញ់ ជាលទ្ធផល ពួកគេបានទទួលរងនូវការឈឺចាប់យ៉ាងខ្លាំងខាងផ្លូវកាយ និងផ្លូវចិត្ត[74] ហើយក៏ទំនងជាបានទទួលរងនូវអំពើហិង្សាខាងផ្លូវភេទ ឬយ៉ាងន័រផងដែរ នៅក្នុងអំឡុងនៃអាពាហ៍ពិពាហ៍។ ដោយសារតែពួកគេមិនធ្លាប់ស្គាល់គ្នាពីមុន ជនរងគ្រោះជួនកាលច្រឡំគូគ្នាក៏មាន[75]។

២៤- កងពលធំ១៦៤ ដាក់ជនរងគ្រោះនៅក្រោមអាពាហ៍ពិពាហ៍ដោយបង្ខំដោយការរៀបការជាបុគ្គល[76] ឬជាក្រុម។ ការរៀបការដោយបង្ខំជាក្រុមចាប់ពីពីរគូ រហូតដល់ម្ភៃគូ នៅក្នុងពិធីរៀបការមហាជនដ៏ធំ[77]។ នៅក្នុងពិធីនេះ ជនរងគ្រោះតម្រូវឲ្យទទួលយកជារៀងរហូតនូវដៃគូដែលគេបានផ្គូផ្គងឲ្យ និងប្រកាសពី "ការតាំងចិត្ត" និង "ការប្តេជ្ញាចិត្ត" របស់ពួកគេ[78]។ ខណៈមានគូស្រករខ្លះ បានស្នើសុំការអនុញ្ញាតដើម្បីរៀបការ គូស្រករខ្លះ ឬការទទួលយកច្បាស់លាស់ជាបុគ្គល ដែលផ្ទុយនឹងឆន្ទៈ

ប្រាកដទេ ប៉ុន្តែខ្ញុំគិតថាគាត់ចង់ឲ្យខ្ញុំជាប់សាច់ជាប់ឈាមជាមួយគាត់ពីព្រោះប្រពន្ធរបស់ខ្ញុំក៏ជាអ្នកដែលជាប់សាច់ឈាមជាមួយគាត់"។ សាក្សីបានលែងលះគ្នានៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ"]។

[74] **D59/1/1.7a** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ា ឈឿន និង ស៊ួន វ៉ាត (Ma Chhoeun and Suon Vat) (DC-Cam), ត្រង់ EN ជាភាសាអង់គ្លេស 00969949-50 ["ប៉ុន្តែ មានអ្នកខ្លះត្រូវគេរៀបចំឲ្យ។ អ្នកខ្លះមិនចូលចិត្តគ្នាទេ ដូច្នេះបញ្ហានឹងកើតឡើងនៅពេលក្រោយ។ ហើយមានប្តីប្រពន្ធខ្លះក៏បានបែកបាក់គ្នា"]។

[75] **D54/29** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ លៀត ឡុន *ហៅ* ណាំ ឡុន, ត្រង់ A7 ["បាទ, មានករណីរៀបការដូច្នេះមែន [នៅក្នុងកងពលធំ១៦៤] ប៉ុន្តែខ្ញុំមិនចាំឈ្មោះមនុស្សដែលរងការប៉ះពាល់ទេ។ ខ្ញុំបានឮថា មានករណីខ្លះ មានប្តីប្រពន្ធពីពីរទៅប្រាំគូ ត្រូវបានគេរៀបការឲ្យក្នុងពេលតែមួយ។ ខ្ញុំក៏បានឮផងដែរថា មានគូស្រកថ្មីថ្មោងខ្លះ ច្រឡំគូគ្នាក៏មាន"]។

[76] សូមមើល **D54/29** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ លៀត ឡុន *ហៅ* ណាំ ឡុន, ត្រង់ A3។

[77] **D59/1/1.7a** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ា ឈឿន និង ស៊ួន វ៉ាត (Ma Chhoeun and Suon Vat) (DC-Cam), ត្រង់ EN ជាភាសាអង់គ្លេស 00969949-50 ["មានគូស្រករជាច្រើន។ គេធ្វើនៅកំពង់សោម។ មនុស្ស៣០នាក់"]។ **D54/29** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ លៀត ឡុន *ហៅ* ណាំ ឡុន, ត្រង់ A7 ["បាទ, មានករណីរៀបការដូច្នេះមែន[ក្នុងកងពលធំ១៦៤] ប៉ុន្តែខ្ញុំមិនចាំឈ្មោះអ្នកដែលប៉ះពាល់ទេ។ ខ្ញុំបានឮថា មានករណីខ្លះ មានគូស្រករពីពីរគូ ទៅប្រាំគូ ត្រូវបានគេរៀបចំឲ្យរៀបការក្នុងពេលតែមួយ]។ **D11/387/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (របាយការណ៍ VSS) របស់ សំ វុទ្ធី, ៣០ មេសា ២០១៤, ត្រង់ ERN ជាភាសាអង់គ្លេស 00991850 ["ពេលគាត់មកដល់ភូមិស្នាច់ដែង សមមិត្ត ឡុន (Lonn) និងប្រធានឃុំ បានបង្ខំឲ្យគាត់រៀបការជាមួយសមមិត្ត ភាព ជាមួយនឹងគូស្រករ ២០គូទៀត ប៉ុន្តែពិធីរៀបការនេះត្រូវបានលុបចោល ដោយសារសមមិត្ត ឈឺ..."]។

[78] **D59/1/1.7a** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ា ឈឿន និង ស៊ួន វ៉ាត (Ma Chhoeun and Suon Vat) (DC-Cam), ត្រង់ EN ជាភាសាអង់គ្លេស 00969949-50 ["គេបានណែនាំយើងឲ្យពង្រឹងទំនាក់ទំនងជាមួយគ្នា មិនត្រូវបែកគ្នាឡើយ។ គេបានបង្រៀនយើង។ យើងមានការតាំងចិត្ត"]។

របស់ពួកគេ ប៉ុន្តែមិនអាចនិយាយប្រាប់ពីការជំទាស់របស់ខ្លួនបាន ដោយសារតែមានការភ័យខ្លាចនូវការសងសឹក[79]។ ក្រោយពេលគូស្រករបានធ្វើការប្តេជ្ញាចិត្តចំពោះមុខអង្គការ ពួកគេត្រូវបានបញ្ជាឱ្យនៅជាមួយគ្នាជាច្រើនថ្ងៃ ដែលអាចសន្មតបាននូវការរួមដំណេកជាមួយគ្នា[80]។ នៅពេលជាមួយគ្នានេះ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅកំពង់សោម និងកងពលធំ១៦៤ ការភ័យខ្លាចគេចោទខុសសីលធម៌ បានច្រានជាមុនមិនឱ្យមនុស្សធ្វើការប្រាស្រ័យទាក់ទងជាមួយបុគ្គលដែលគេចង់រៀបការជាមួយ[81]។

## ការកំណត់បទចោទ

២៥- សហព្រះរាជអាជ្ញា មានហេតុផលនាំឱ្យជឿបានថា អង្គហេតុទាំងឡាយដូចបានរៀបរាប់ខាងលើ (កថាខណ្ឌ៦ ដល់ ២៤) រួមបង្កើតបានជាឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ រួមទាំង ប៉ុន្តែមិនកម្រិតត្រឹមចំពោះ៖

ក. ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឱ្យទៅជាទាសករ អំពើអមនុស្សធម៌ផ្សេងៗ ការធ្វើទារុណកម្ម ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជ

---

[79] **D54/29** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ លៀត ឡូន *ហៅ*ណាំ ឡូន, ត្រង់ A3 (EN 00976573) ["… គាត់បានស្នើឱ្យកូនកម្លោះ និងកូនក្រមុំ ធ្វើការប្រកាស។ ទីប្រាំ គេស្នើឱ្យបញ្ជាក់ថាតើ ពួកគេព្រមព្រៀងគ្នាជាប្តីប្រពន្ធឬអត់។ ក្រោយមក កូនក្រមុំក៏និយាយថា ខ្លួនយល់ព្រមរៀបការ។ ខ្ញុំអត់និយាយអ្វីទាំងអស់ ព្រោះខ្ញុំអត់ពេញចិត្តនឹងព្រឹត្តិការណ៍នេះទេ ដោយសារខ្ញុំអត់បានដឹងអ្វីទាំងអស់អំពីការរៀបការនេះ…។ បន្ទាប់មក ខាងឪពុកម្តាយខាងស្រី និងកម្មាភិបាលជាន់ខ្ពស់ប្រកាសថា យើងជាប្តីប្រពន្ធនឹងគ្នា"]។ A6 ["ខ្ញុំគ្មានជម្រើសអ្វីទាំងអស់។ ខ្ញុំត្រូវតែទទួលយកការរៀបការដែលគេបានរៀបចំឱ្យនេះ។ បើមិនដូច្នោះទេ គេនឹងដកខ្ញុំចេញពីការងារ និងបញ្ជូនទៅកន្លែងផ្សេងជាមិនខាន"]។ A5 ["ខ្ញុំមានការភ្ញាក់ផ្អើលអំពីការរៀបចំនេះ។ តាំងពីនោះមក ខ្ញុំបាត់បង់ការជឿទុកចិត្តលើវិធីធ្វើការងាររបស់របបនេះ"]។ **D59/1/1.7a** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ា ឈឿន និង ស៊ួន វ៉ាត (Ma Chhoeun and Suon Vat) (DC-Cam), ត្រង់ EN ជាភាសាអង់គ្លេស 00969949-50 ["ប៉ុន្តែ មានមនុស្សខ្លះត្រូវគេរៀបចំឱ្យ ហើយខ្លះទៀតមិនដូចគ្នាទេ ដូច្នេះហើយ ក៏កើតមានបញ្ហានៅពេលក្រោយ និងមានប្តីប្រពន្ធខ្លះ ក៏បែកគ្នា"]។

[80] **D54/29** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ លៀត ឡូន *ហៅ*ណាំ ឡូន, ត្រង់ A3 (EN 00976573) ["ក្រោយមក *តា* ញ៉ន (*Ta* Nhan) បានប្រាប់ខ្ញុំឱ្យនៅផ្ទះមួយដែលគេបានត្រៀមរួចជាស្រេចសម្រាប់យើងទាំងពីរនាក់។ ប្រហែលមួយសប្តាហ៍ក្រោយពីបានរស់នៅជាមួយប្រពន្ធខ្ញុំ ខ្ញុំក៏បានវិលត្រឡប់ទៅកាន់កប៉ាល់វិញដើម្បីហ្វឹកហ្វឺនទាហាន។ ប្រពន្ធខ្ញុំក៏ត្រឡប់ទៅធ្វើការរបស់គាត់វិញនៅកងផលិត… ខ្ញុំបានរៀបការក្នុងឆ្នាំ១៩៧៨"]។

[81] **D54/43** កំណត់ហេតុស្តាប់ចម្លើយសាក្សី កសចស លើឈ្មោះ លុន សេង, [ប្រធានកងវរៈសេនាតូច៤២០ កងពលធំ១៦៤], ត្រង់ A17 ["យើងមិនហ៊ាននិយាយជាមួយនារីដែលយើងចង់រៀបការជាមួយទេ ព្រោះយើងមិនចង់ឱ្យគេចោទថា យើងខុសសីលធម៌"]។

សាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត រួមបង្កើតបានជា **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ដែលត្រូវផ្តន្ទាទោសនៅក្រោមមាត្រា៥, មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

ខ. ឧក្រិដ្ឋកម្មនៃការបង្ខាំងជនស៊ីវិលដោយខុសច្បាប់ ការដកហូតដោយចេតនាពីឈ្លើយសឹកឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយឬសុខភាព ការធ្វើទារុណកម្ម និងការធ្វើមនុស្សឃាតដោយចេតនា។ អំពើទាំងនេះ បង្កើតបានជា **អំពើបំពានបំពានយ៉ាងធ្ងន់ធ្ងរ នៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩** ដែលត្រូវផ្តន្ទាទោសក្រោមមាត្រា៦ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

២៦- សហព្រះរាជអាជ្ញា មានហេតុផលនាំឲ្យជឿបានថា **មាស មុត** និងមេដឹកនាំជាន់ខ្ពស់/ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតដទៃទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យ បានប្រព្រឹត្ត បានធ្វើផែនការ បានញុះញង់ បានបញ្ជា ឬបានជួយនិងទំនុកបម្រុង លើអំពើព្រហ្មទណ្ឌជាក់លាក់ដូចបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ ដែលបង្កើតបានជាបទល្មើសនៅក្រោមច្បាប់ អ.វ.ត.ក។ អំពើទាំងនេះ គឺជាផ្នែកនៃផែនការឧក្រិដ្ឋកម្មរួម ឬសហឧក្រិដ្ឋកម្មរួម[82]។

២៧- ឯកសារទាំងប៉ុន្មានដែលបានលើកយោងក្នុងដីកាសន្និដ្ឋានបន្ថែមនេះ ដែលចេញពីសំណុំរឿង ០០២ ហើយដែលបានស្នើឲ្យដាក់បញ្ចូលទៅក្នុងសំណុំរឿង០០៣ ត្រូវបានចុះបញ្ជីក្នុង **ឧបសម្ព័ន្ធ១** ដែលភ្ជាប់ទៅជាមួយ។ កសចស ត្រូវបានផ្តល់សិទ្ធិដោយអង្គជំនុំជម្រះសាលាដំបូងឲ្យចូលពិនិត្យមើល

[82] ការពិនិត្យឡើងវិញលើផែនការឧក្រិដ្ឋកម្មរួម ដូចបានរៀបរាប់ក្នុងកថាខណ្ឌ៣៣-៤១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ កំពុងតែត្រៀមរៀបចំហើយ។ ថ្ងៃចាប់ផ្តើមដំបូងនៃផែនការនេះ ព្រមទាំងសមាជិក និងគោលបំណងរបស់ផែនការ នឹងត្រូវកែសម្រួលឲ្យស្របទៅតាមស្ថានភាពបច្ចុប្បន្ននៃភ័ស្តុតាងដែលប្រមូលបាន។

ឯកសារសម្ងាត់ក្នុងសំណុំរឿង០០២ និងត្រូវបានផ្តល់អំណាចឲ្យដាក់ឯកសារទាំងនេះទៅក្នុងសំណុំរឿងនេះ[83]។

២៨- ដីកាសន្និដ្ឋានបន្ថែមនេះ ត្រូវបានចុះហត្ថលេខាដោយសហព្រះរាជអាជ្ញាអន្តរជាតិ បើដូច្នេះ ឯកសារនេះត្រូវបានដាក់អនុលោមតាមវិធាន៧១(៣) នៃវិធានផ្ទៃក្នុង។ កំណត់ហេតុនៃការខ្វែងយោបល់គ្នាត្រូវបានដាក់ចូលទៅក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នា ដោយរក្សាទុកដោយក្រឡាបញ្ជីរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៧១(១)។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
| --- | --- | --- | --- |
| ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

[83] **D53/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង, ២២ វិច្ឆិកា ២០១២។